ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ឯកសារណែនាំបច្ចេកទេស

# សំរាប់

# អ្នកសំរបសំរួលដំណើរការរៀបចំកម្មវិធីវិនិយោគ

# បីឆ្នាំរំកិលរបស់ឃុំ សង្កាត់

រៀបចំដោយក្រុមការងារក្រសួងផែនការនិងក្រសួងកិច្ចការនារី

ឧសភា ឆ្នាំ២០០៥

# បុព្វកថា

កន្លងមក ដើម្បីជាជំនួយដល់ការរៀបចំកម្មវិធីវិនិយោគរបស់ឃុំ សង្កាត់ ក្រសួងផែនការបានចេញនូវសេចក្ដីណែនាំបច្ចេកទេស ស្ដីពីការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំសង្កាត់ ហើយក្រសួងកិច្ចការនារី ក៏បានចេញនូវសេចក្ដីណែនាំជាជំនួយស្មារតីក្នុងការបញ្ជ្រាបយេនឌ័រ ។ ដោយសេចក្ដីណែនាំទាំងពីរនេះនៅដោយឡែកពីគ្នា តាមការអនុវត្តជាក់ស្ដែងនៅក្នុងឆ្នាំ២០០៤ មន្ត្រីនិងអ្នកចូលរួមកសាងផែនការវិនិយោគបីឆ្នាំរំកិលរបស់ឃុំសង្កាត់ បានជួបការលំបាកក្នុងការប្រើប្រាស់ខ្លឹមសារឯកសារទាំងពីរនេះអោយមានសង្គតិភាព ។ ក្នុងគោលបំណងសំរួលដល់បញ្ហានេះ ក្រុមការងារសិលាក្រសួងផែនការ និងក្រសួងកិច្ចការនារី បានរៀបចំកែសម្រួល និងចងក្រងសេចក្ដីណែនាំបច្ចេកទេសថ្មីនេះ សំរាប់ជាជំនួយស្មារតីជូនដល់ មន្ត្រីនិងអ្នកចូលរួមកសាងផែនការវិនិយោគបីឆ្នាំរំកិលរបស់ឃុំសង្កាត់ ។

សេចក្ដីណែនាំបច្ចេកទេសថ្មីនេះ ជាឯកសារសំយោគរវាងសេចក្ដីណែនាំបច្ចេកទេសស្ដីពីការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំសង្កាត់ ដែលចេញដោយក្រសួងផែនការនិងសេចក្ដីណែនាំជំនួយស្មារតីក្នុងការបញ្ជ្រាបយេនឌ័រដែលចេញដោយក្រសួងកិច្ចការនារី ។ សេចក្ដីណែនាំបច្ចេកទេសថ្មីនេះ ជាសេចក្ដីណែនាំជំនួសអោយសេចក្ដីណែនាំចាស់ទាំងពីរខាងលើ ។ យើងខ្ញុំ សូមអោយមន្ត្រីគ្រប់ថ្នាក់ដែលចូលរួមក្នុងការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំ សង្កាត់មាន : ក្រុមប្រឹក្សាឃុំ សង្កាត់ គណៈកម្មាធិការផែនការនិងថវិកាឃុំ សង្កាត់ អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំសង្កាត់ អ្នកសម្របសម្រួលថ្នាក់ខេត្តក្រុង ស្រុកខណ្ឌ និងអ្នកពាក់ពន្ធ័ទាំងអស់ យកសេចក្ដីណែនាំបច្ចេកទេសថ្មីនេះ ទៅធ្វើការពិចារណាស្វែងយល់និងប្រើប្រាស់ប្រកបដោយគុណភាព ។

ខ្ញុំសូមកោតសរសើរដោយស្មោះចំពោះ ក្រុមការងារកម្មវិធីសិលានៃក្រសួងផែនការ ក្រុមការងារគាំទ្រការបញ្ជ្រាបយេនឌ័រក្នុងកម្មវិធិសិលានៃក្រសួងកិច្ចការនារី ក្រុមការងារកម្មវិធីសិលានៃក្រសួងមហាផ្ទៃ មន្ត្រីគំរោងភាពជាដៃគូសម្រាប់អភិបាលកិច្ចមូលដ្ឋាន មន្ត្រីកម្មវិធីសិទ្ធិកុមារនៃអង្គការយូនីសេហ្វ និងមន្ត្រីពាក់ពន្ធ័ទាំងអស់ ដែលបានខិតខំរៀបចំសេចក្ដីណែនាំបច្ចេកទេសថ្មីនេះ ។

រាជធានីភ្នំពេញ, ថ្ងៃទី 11 ខែឧសភា ឆ្នាំ២០០៥

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**

**ឆាយ ថន**

**រដ្ឋមន្ត្រីក្រសួងកិច្ចការនារី**

**អ៊ឹង កន្ថាផាវី**

Pla-com?

បណ្ណាល័យ
គ.ជ.អ.ប

library.ncdd.gov.kh
002990

354-968
INV

sh: Training

# មាតិកា

## ផ្នែកទី១ : ទំរង់ឯកសារកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់ឃុំ សង្កាត់


អារម្ភកថា ---------------------------------------------------------------------------- ១

សេចក្តីផ្តើម ---------------------------------------------------------------------------- ១

ផែនទី ---------------------------------------------------------------------------- ១

ជំពូកទី១ : ការវិភាគពីស្ថានភាពអភិវឌ្ឍន៍របស់ឃុំ សង្កាត់

ក) ផ្នែកសេដ្ឋកិច្ច ---------------------------------------------------- ២

ខ) ផ្នែកសង្គមកិច្ច ---------------------------------------------------- ២

គ) ផ្នែកធនធានធម្មជាតិនិងបរិស្ថាន ------------------------------------ ៣

ឃ) ផ្នែកសេវាកម្មរដ្ឋបាល និងសន្តិសុខ ---------------------------------- ៣

ង) ផ្នែកយេនឌ័រ ---------------------------------------------------- ៤

ជំពូកទី២ : ទិសដៅបន្ទាន់ និងយុទ្ធសាស្ត្រសំរាប់ការវិនិយោគ

ក) ទិសដៅបន្ទាន់ ---------------------------------------------------- ៤

ខ) យុទ្ធសាស្ត្រសំរាប់ការវិនិយោគ ---------------------------------------- ៥

ជំពូកទី៣ : គំរោងវិនិយោគបីឆ្នាំរំកិល

ក) តារាងគំរោងវិនិយោគឃុំសង្កាត់បីឆ្នាំរំកិល ------------------------------ ៥

ខ) តារាងថវិកាវិនិយោគតាមប្រភពផ្តល់ ------------------------------------ ៥

ឧបសម្ព័ន្ធ : ---------------------------------------------------------------------------- ៥


## ផ្នែកទី២ : វិធីសាស្ត្ររៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំសង្កាត់តាមជំហាននិមួយៗ


ជំហានទី១ : ការកំណត់បញ្ហាឬតំរូវការនៅថ្នាក់ឃុំ សង្កាត់ ------------------------------ ៦

ជំហានទី២ : ការប្រជុំពិភាក្សាជាមួយប្រជាជនក្នុងភូមិ ------------------------------ ១១

ជំហានទី៣ : ការប្រជុំកំណត់បញ្ហាឬតំរូវការនៅឃុំសង្កាត់ ------------------------------ ១៥

ជំហានទី៤ : ការកំណត់ទិសដៅនិងយុទ្ធសាស្ត្រវិនិយោគ ------------------------------ ២៣

ជំហានទី៥ : ការកំណត់គំរោងដែលត្រូវវិនិយោគ ------------------------------ ២៥

ជំហានទី៦ : ការព្យាករណ៍ទុនវិនិយោគ ------------------------------ ២៧

ជំហានទី៧ : ការរៀបចំតារាងគំរោងវិនិយោគជាអាទិភាព ------------------------------ ២៩

ជំហានទី៨ : ការរៀបចំសមាហរណកម្មផែនការថ្នាក់ស្រុកខណ្ឌ ------------------------------ ៣៣

ជំហានទី៩ : ការសំរេចចុងក្រោយលើគំរោងនានាក្នុងកម្មវិធីវិនិយោគឃុំសង្កាត់ ---------- ៣៤

ជំហានទី១០ : ការចងក្រងសៀវភៅកម្មវិធីវិនិយោគឃុំសង្កាត់ ------------------------------ ៤០

ជំហានទី១១ : ការរៀបចំអនុម័តឯកសារកម្មវិធីវិនិយោគឃុំសង្កាត់ ------------------------------ ៤១

# ផ្នែកទី១

# ទំរង់ឯកសារកម្មវិធីវិនិយោគ
# ៣ឆ្នាំរំកិលរបស់ឃុំ សង្កាត់

# ផ្នែកទី១

ការពន្យល់ខាងក្រោមនេះ គ្រាន់តែជាការណែនាំអោយយល់ពីអត្ថន័យនៃចំនុចនិមួយៗ ដែលត្រូវសរសេរឯកសារកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំសង្កាត់ប៉ុណ្ណោះ ។ ហេតុនេះ ឃ្លាប្រយោគដែលត្រូវសរសេរ គឺត្រូវរៀបរាប់តាមសភាពជាក់ស្តែង ដោយប្រើប្រាស់ពាក្យពេចន៍ផ្សេងៗ ដែលបានលើកឡើងក្នុងពេលពិភាក្សា ។ សូមចងចាំថា សេចក្តីពន្យល់ និងឧទាហរណ៍ខ្លះៗខាងក្រោម គ្រាន់តែជាជំនួយស្មារតីសំរាប់សរសេរចងក្រង មិនមែនជាឃ្លាប្រយោគដែលត្រូវចំលងចូលក្នុងឯកសារឡើយ ។

**អារម្ភកថា** : ជាការសង្ខេបអំពីខ្លឹមសារផ្នែកខាងក្នុង ដើម្បីអោយមានការទាក់ទាញអារម្មណ៍ ដែលបញ្ចាប់ដោយឃ្លាប្រយោគថ្លែងអំណរគុណផ្សេងៗ និងហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាឃុំសង្កាត់ ដែលបញ្ជាក់ពីការអនុម័តយល់ព្រម របស់ក្រុមប្រឹក្សាឃុំសង្កាត់ទាំងមូល ទៅលើឯកសារនេះ ព្រមទាំងមានបោះត្រាឃុំសង្កាត់ ។

**សេចក្តីផ្តើម** : ត្រូវសរសេររៀបរាប់ដោយសង្ខេប ពីមូលហេតុនិងគោលបំណងសំខាន់ៗដែលនាំអោយមានការរៀបចំកម្មវិធីវិនិយោគនេះ ។

**ផែនទី** : ដោយបង្ហាញពីទីតាំងសំខាន់ៗនៃ :

- ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជា ផ្លូវថ្នល់ មន្ទីរពេទ្យ សាលារៀន ប្រឡាយទឹក វត្តអារាម ។ល។
- ធនធានធម្មជាតិ ដូចជា វាលស្រែ បឹង ថ្លុកត្រពាំង តំបន់ព្រៃការពារ តំបន់ព្រៃ ។ល។
- សេវាសាធារណៈ ផ្សារ កំពង់ចំលង ចំណតរថយន្ត រមណីយដ្ឋាន ។ល។

ផែនទីដែលគូសឡើងនេះ គ្រាន់តែជាផែនទីណែនាំ ដោយមិនមានមាត្រដ្ឋានត្រឹមត្រូវទេ ។ ដើម្បីអោយងាយមើល ឃុំសង្កាត់ អាចប្រើផែនទីច្រើនផ្ទាំង ទៅតាមខ្លឹមសារដោយឡែកៗដូចជា ផែនទី ១សន្លឹក បង្ហាញពីទីតាំងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសេវាសាធារណៈមួយសន្លឹក បង្ហាញពីទីតាំង ធនធានធម្មជាតិ ។

## ជំពូកទី១ : ការវិភាគពីស្ថានភាពអភិវឌ្ឍន៍របស់ឃុំសង្កាត់

អ្នកសំរបសំរួលត្រូវណែនាំគ.ផ.ថ ថា ដើម្បីសរសេរជំពូកនេះត្រូវផ្អែកលើសេចក្តីសន្និដ្ឋានសរុបនៃការវិភាគពត៌មានស្តីពីស្ថានភាពឃុំសង្កាត់ ។

ក) ផ្នែកសេដ្ឋកិច្ច

ផ្នែកនេះជាបញ្ហាឬសក្តានុពលទាក់ទងទៅនឹងអ្វី ដែលជាស្ថានភាពសេដ្ឋកិច្ចរបស់ឃុំ សង្កាត់ ដូចជា កសិកម្ម ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ។ល។ ដោយគិតរួមបញ្ចូលទាំងភាព ខ្លាំង ឬសក្តានុពលភាព ខាងទីផ្សារ ខាងផលិត ដែលមានក្នុងឃុំ សង្កាត់ទាំងមូល ។

ឧទាហរណ៍ : ឃុំអូរសណ្តាន់ ស្រុកក្រគរ ខេត្តពោធិសាត់ (ហាមចំឡងទាំងស្រុង)

ឃុំអូរសណ្តាន់ មានទីតាំងនៅជាប់មាត់ទន្លេសាប ដែលប្រជាជនភាគច្រើន ប្រកបរបរនេសាទត្រីជាចំណូលសំខាន់ ។ មានតែភូមិពីរ គឺភូមិពុទ្រាម និងភូមិថ្មីង ដែលមានប្រព័ន្ធធារាសាស្ត្រល្អប្រសើរ អំណោយផលដល់ការធ្វើស្រែវស្សា ។ ប៉ុន្តែ ប្រព័ន្ធនេះពុំបានប្រើប្រាស់អស់សក្តានុពលនៅឡើយ ដោយទិន្នផលស្រូវនៅទាប ។ ការប្រើប្រាស់ប្រព័ន្ធនេះ សំរាប់ធ្វើស្រូវប្រាំងក៏ពុំទាន់អាចធ្វើទៅបានដែរ ។ ការលំបាកកន្លងមកដែលឃុំជួបប្រទះគឺគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតដែលធ្វើអោយលិចលង់ខូចស្រូវឡើងទឹកនៅភូមិចុងខ្ទង់ និងស្ងួតខូចសន្ទូងនៅភូមិក្រាំងធំ ។ សេវាភ្នូររាស់ដោយគ្រាក់ទ័រ អាចរកបានពីឃុំផ្សេងនៅជិត១នេះ ។ ផ្លូវគមនាគមន៍ មានភាពល្អប្រសើរនៅរដូវប្រាំង ចំណែករដូវវស្សាវិញ ការធ្វើដំណើរក្នុងភូមិមួយចំនួនត្រូវជំនួសដោយទូក-កាណូតវិញ ។ សក្តានុពលសេដ្ឋកិច្ចដ៏សំខាន់របស់ឃុំអូរសណ្តាន់ គឺផលនេសាទ ។ ទីផ្សារសំខាន់របស់ ប្រជាជនក្នុងឃុំអូរសណ្តាន់គឺផ្សារក្រគរ ។ ប៉ុន្តែ ការកែច្នៃផលនេសាទ ដើម្បីរក្សាទុកបានយូរនិងមានគុណភាព គួបផ្សំ និងការវេចខ្ចប់ប្រកបដោយសោភ័ណ្ឌភាព ដែលជាផ្នែកមួយនៃការបន្ថែមតំលៃ (Value added) ទៅលើ ផលនេសាទរបស់ប្រជាជននៅក្នុងភូមិ ហាក់ពុំទាន់មានការយកចិត្តទុកដាក់នៅឡើយ ។

ខ) ផ្នែកសង្គមកិច្ច

ផ្នែកនេះគឺអ្វីដែលទាក់ទងទៅនឹងបញ្ហាឬសក្តានុពល ក្នុងវិស័យសង្គមកិច្ចដូចជា អប់រំ សុខាភិបាល សាសនា ។ល។ ព្រោះក្រៅពីបញ្ហា តើអាចមានអ្វីដែលជាចំនុចខ្លាំង (សក្តានុពល) ជួយជំរុញកិច្ចអភិវឌ្ឍន៍ឃុំសង្កាត់បាន ។

ឧទាហរណ៍ : ឃុំអូរសណ្តាន់ ស្រុកក្រគរ ខេត្តពោធិសាត់ (ហាមចំឡងទាំងស្រុង)

ការលំបាកដែលឃុំត្រូវប្រឈមចំពោះមុខ គឺកុមារភាគច្រើនមិនបានបានចូលរៀន ។ បញ្ហាក្រុមជនងាយរងគ្រោះ ដូចជាជនពិការ ស្ត្រីមេម៉ាយ និងមនុស្សចាស់ជរា គឺជាបញ្ហាកង្វល់របស់ឃុំអូរសណ្តាន់ ហើយកុមារភាគច្រើនដែលមិនបានទៅសាលារៀន គឺជាកុមារដែលស្ថិតក្នុងប្រភេទគ្រួសារក្រីក្រទាំងនោះ ។ ឃុំក៏ជួបប្រទះនូវការលំបាកដោយសារគ្មានសាលានៅជិតភូមិ ដើម្បីជួយសំរួលដល់ការចូលរៀនរបស់កុមារក្នុងភូមិមួយចំនួន ។ ចំនួនអនក្ខរជនក្នុងឃុំ មានច្រើនជាបង្គួរ ហើយថ្នាក់អក្ខរកម្មដែលពុំបានបើកជាប្រចាំនោះ បាននាំមកនូវគ្រោះភ្លេចអក្សរ ក្នុងចំនោមអ្នកដែលបានចូលមកសិក្សាក្នុងថ្នាក់អក្ខរកម្មកន្លងមក ។ ទោះបីជាយ៉ាងណាឃុំក៏អាចសំរេចបានបានជោគជ័យលើផ្នែកបង្គន់អនាម័យ ក្រោមការជួយគាំទ្ររបស់អង្គការ RSCD និងផ្នែកទឹកស្អាតប្រើប្រាស់ក្នុងគ្រួសារ ។ បញ្ហាសុខភាព បានស្ថិតនៅជាអាទិភាពចំបងរបស់ឃុំ ដោយសារតែមណ្ឌលសុខភាពនៅឆ្ងាយ ហើយ

សេវាដឹកជញ្ជូនអ្នកជំងឺធាប់រហ័ស ហាក់ពុំទាន់ដោះស្រាយបាននៅឡើយ ។ ម្យ៉ាងទៀត ប្រជាជនក៏ពុំទាន់មានទំនុកចិត្ត លើផ្នែកវេជ្ជសាស្ត្របច្ចុប្បន្នទាំងស្រុងឡើយ ។

គ) ផ្នែកធនធានធម្មជាតិនិងបរិស្ថាន

គឺជាស្ថានភាពផ្លាស់ប្តូរ ឬការសឹករិចរិល ឬឥទ្ធិពលនានាដែលកើតមាននៅក្នុងឃុំ សង្កាត់ ទាក់ទងនឹងធម្មជាតិ បឹងបួរ ទន្លេ ភ្នំ ប្រាសាទបុរាណ ព្រៃធម្មជាតិ ព្រមទាំងការបំពុលទឹក ខ្យល់អាកាស សំឡេង ដែលកំពុងមានឬបំរុងនឹងកើតមាន ជាផលប៉ះពាល់ចំពោះជីវិតរស់នៅរបស់ប្រជាជន ។ ក្រៅពីបញ្ហា ឃុំសង្កាត់ក៏ត្រូវលើកឡើងពីចំនុចខ្លាំង ជាសក្តានុពលភាព សំរាប់ជួយជំរុញការងារអភិវឌ្ឍន៍លើផ្នែកនេះបានដែរ ។

ឧទាហរណ៍ : ឃុំអូរសណ្តាន់ ស្រុកក្រគរ ខេត្តពោធិសាត់ ( ហាមចំឡងទាំងស្រុង)

ដោយសារឃុំនេះ ស្ថិតនៅជាប់មាត់បឹងទន្លេសាប ហេតុនេះ ផលប៉ះពាល់ដែលអាចកើតមានដល់បរិស្ថាន គឺការកាប់ព្រៃលិចទឹក និងការប្រើប្រាស់ឧបករណ៍ធក់ត្រីប្រចាំគ្រួសារ ។ ចំណែកការប្រើប្រាស់ជីរគីមី និងថ្នាំសំលាប់សត្វល្អិត ពុំមានផលប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថានដែលគួរកង្វល់ឡើយ ។ ការរៀបចំសហគមន៍នេសាទ ដើម្បីប្រើប្រាស់ធនធានព្រៃលិចទឹក និងមច្ឆាជាតិប្រកបដោយនិរន្តរភាព គឺជាដំណោះស្រាយសមស្របបំផុត សំរាប់ឃុំអូរសណ្តាន់នាពេលបច្ចុប្បន្ន ។

ឃ) ផ្នែកសេវាកម្មរដ្ឋបាល និងសន្តិសុខ

សេវាកម្មរដ្ឋបាល សំដៅលើការងារទាំងឡាយដែលឃុំសង្កាត់ ជួបប្រទះក្នុងការបំពេញការងាររដ្ឋបាលប្រចាំថ្ងៃ ដូចជា ការចុះអត្រានុកូលដ្ឋាន ការចុះសំបុត្រអាពាហ៍ពិពាហ៍ ដោះស្រាយទំនាស់ផ្សេងៗ ។ល។ ដូចបានកំណត់នៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ ។ ផ្នែកនេះ ឃុំសង្កាត់ ត្រូវពិពណ៌នាអំពីបញ្ហាជួបប្រទះ ដូចជា សាមគ្គីភាពផ្ទៃក្នុង សមត្ថភាពយល់ដឹងលើផ្នែកណាមួយ ការងារសំរបសំរួលជាមួយអង្គការ សមាគម មន្ទីរជំនាញ....។ល។ ក្នុងផ្នែកនេះដែរ ឃុំសង្កាត់ ក៏ត្រូវបង្ហាញពីស្ថានភាពសន្តិសុខសណ្តាប់ធ្នាប់សង្គមដែលកំពុងមានបច្ចុប្បន្ន និងមូលហេតុមួយចំនួនដែលពាក់ព័ន្ធផងដែរ ។

ឧទាហរណ៍ : ឃុំអូរសណ្តាន់ ស្រុកក្រគរ ខេត្តពោធិសាត់ ( ហាមចំឡងទាំងស្រុង)

បញ្ហាសន្តិសុខ មិនមែនជាបញ្ហាចោទធ្ងន់ធ្ងរសំរាប់ការដោះស្រាយបន្ទាន់នៅក្នុងឃុំអូរសណ្តាន់ឡើយ ។ ប៉ុន្តែទោះជាយ៉ាងណា ក្រុមប្រឹក្សាឃុំ ត្រូវមានការយល់ដឹងបន្ថែម អំពីនីតិវិធីក្នុងការដោះស្រាយទំនាស់ក្រៅតុលាការបន្ថែមទៀត ។ ដើម្បីជៀសវាងទំនាស់ដីធ្លីផ្សេងៗ ប្រជាជនត្រូវមានប្លង់ដីដែលបញ្ជាក់ពីព្រំប្រទល់ច្បាស់លាស់ ។ សមាជិកក្រុមប្រឹក្សាឃុំ ត្រូវយល់ពីច្បាប់ភូមិបាលអោយបានច្បាស់លាស់ ។ ការដោះស្រាយបញ្ហាទំនាស់តិចតួចប្រកបដោយគតិយុត្តិធម៌ គឺជាវិធានការការពារទុកជាមុនដ៏សមស្របបំផុតដែលឃុំនឹងប្រកាន់យក ដើម្បីការពារទំនាស់កុំអោយរីករាលដាលខ្លាំងឡើង ។

ង) <u>ផ្នែកយេនឌ័រ</u>

ផ្នែកនេះ គឺសំដៅលើបញ្ហាមួយចំនួនដែលទាក់ទងដល់ការរស់នៅ ក្នុងសង្គមរបស់បុរសនិងស្ត្រី ដូចជា ការបែងចែកសិទ្ធនិងតួនាទី ជាដើម ។ ផ្នែកនេះ គួរលើកឡើង ពីបញ្ហាជួបប្រទះ ដូចជា វិសមភាពយេនឌ័រក្នុងការអប់រំ ក្នុងគ្រួសារ ក្នុងគណៈកម្មការ ក្នុងការធ្វើការសំរេចក្នុងការដឹកនាំ ក្នុងការទទួលផលពីគំរោងឬកម្មវិធីនានា ...។ល។ ជាធម្មតា ជនបង្គោលយេនឌ័រ ដែលបានទទួលការបណ្តុះបណ្តាលនៅឃុំ សង្កាត់អាចយល់ និងជួយពន្យល់បានក្នុងផ្នែកនេះ ។ ក្រៅពីបញ្ហា ក៏គួរលើកឡើងពីចំនុចខ្លាំងដែលមានជាយុទ្ធសាស្ត្រមួយចំនួន ដែលទាក់ទងដល់ការដោះស្រាយតំរូវការនានា សំរាប់ជួយសំរួលឬជួយជំរុញភាពធូរស្រាលផ្នែកយែនឌ័រផងដែរ។

<u>ឧទាហរណ៍</u> : ឃុំអូរសណ្តាន់ ស្រុកក្រគរ ខេត្តពោធិសាត់ (ហាមចំឡងទាំងស្រុង)

តាមពត៌មានស្ថានភាពឃុំ ក៏ដូចជាស្ថានភាពជាក់ស្តែងដែលយើងទាំងអស់គ្នាធ្លាប់ដឹង នៅឃុំអូរសណ្តាន់ មិនមានការប្រកាន់បែងចែកគ្នារវាងស្ត្រីនិងបុរស ឬរវាងកូនស្រីនិងកូនប្រុសដែលមានលក្ខណៈធ្ងន់ធ្ងរគួរកត់សំគាល់នោះទេ ។ ភាគរយក្មេងស្រីនិងក្មេងប្រុស មិនបានចូលរៀននៅតាមភូមិនិមួយៗ មានប្រហាក់ប្រហែលគ្នា ហើយភាគរយស្ត្រីនិងបុរស មិនចេះអក្សរ ក៏ប្រហាក់ប្រហែលគ្នាដែរ ។ ទោះជាមានអំពើហឹង្សាក្នុងគ្រួសារ កើតមានឡើងស្ទើរគ្រប់ភូមិ តែវាគ្រាន់តែជាប្រភេទទំនាស់គ្រួសារធម្មតារវាងប្តីប្រពន្ធ មិនអាចចាត់ទុកថាជាការរំលោភបំពានដោយអំណាចរបស់បុរសទៅលើស្ត្រី ដែលបណ្តាលមកពីទំនៀមទំលាប់យូរលង់របស់ឃុំ អូរសណ្តាន់ឡើយ ។ ផ្ទុយទៅវិញ ប្រពៃណីនៅភូមិពុទ្រាមដែលបង្គាប់អោយកូនកំលោះសង់ផ្ទះមុនពេលរៀបការ បានលើកតំកើងតំលៃកូនស្រីយ៉ាងខ្លាំងទៀតផង ។ ការរៀបចំអោយមានវគ្គបណ្តុះបណ្តាលស្តីពីបញ្ហាយេនឌ័រ និងអំពើហឹង្សាក្នុងគ្រួសារនៅក្នុងឃុំអូរសណ្តាន់ បានរួមចំណែកកាត់បន្ថយអំពើហឹង្សាក្នុងគ្រួសារបានយ៉ាងច្រើន ។ បញ្ហាចោទខ្លាំងដែលឃុំកំពុងពិចារណារកដំណោះស្រាយ គឺគ្រួសារដែលមានស្ត្រីជាមេគ្រួសារហើយមានកូនតូចជាង៥ឆ្នាំកំពុងស្ថិតក្នុងបន្ទុកដែលភាគច្រើន គឺនៅភូមិក្រាំងធំ ។ គ្រួសារទាំងនេះ កំពុងជួបការលំបាកយ៉ាងខ្លាំង ក្នុងការរកប្រាក់ចំណូលចិញ្ចឹមជីវិត ព្រោះថា ស្ត្រីទាំងនោះ ត្រូវរកប្រាក់ចំណូលចិញ្ចឹមគ្រួសារផង និងត្រូវមើល ថែទាំកូនតូចៗរបស់ខ្លួនផង ។ ប្រការនេះ អាចបណ្តាលអោយកូនតូចៗទាំងនោះ ងាយធ្លាក់ទៅក្នុងស្ថានភាពកង្វះអាហាររូបត្ថម្ភជាងកុមាររស់នៅក្នុងគ្រួសារធម្មតា ។

## ជំពូកទី២ : ទិសដៅបន្ទាន់ និងយុទ្ធសាស្ត្រសំរាប់ការវិនិយោគ

អ្នកសំរបសំរួល ត្រូវបញ្ជាក់ជូន គ.ផ.ថ ថា ដើម្បីសរសេរជំពូកនេះ ត្រូវផ្អែកលើលទ្ធផលនៃការពិភាក្សា និងឯកភាពនៅក្នុងជំហានទី៤ ។

ក) <u>ទិសដៅបន្ទាន់</u>

ជាបំណងប្រាថ្នាដែលសង្ឃឹមថា នឹងទទួលបាននៅក្រោយពីការអនុវត្តគំរោងវិនិយោគ ។ ទិសដៅ គឺជាឃ្លាអធិប្បាយជាពាក្យពេចន៍ដែលបង្ហាញកំរិតនៃស្ថានភាព ដែលសង្ឃឹមថាទទួលបានក្រោយពីបានអនុវត្តគំរោង ឬធ្វើសកម្មភាពណាមួយ ។

ខ) <u>យុទ្ធសាស្ត្រសំរាប់ការវិនិយោគ</u>

គឺជាវិធី ឬមាគ៌ា ឬជំរើសណាមួយដែលឃុំ សង្កាត់យល់ថា ល្អប្រសើរបំផុតក្នុងការអនុវត្ត ដើម្បីអាចសំរេចបាននូវទិសដៅដែលជាបំណងប្រាថ្នាខាងលើ ។

## ជំពូកទី៣ : គំរោងវិនិយោគបីឆ្នាំរំកិល

កម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំសង្កាត់ គឺជាឯកសារគំរោងវិនិយោគដែលរៀបចំឡើង សំរាប់អនុវត្តក្នុងរយៈពេល៣ឆ្នាំជាបន្តបន្ទាប់ តាមលក្ខណៈរំកិលពីមួយឆ្នាំទៅមួយឆ្នាំ ។ អត្ថប្រយោជន៍នៃការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលនេះ គឺផ្តល់ភាពងាយស្រួលក្នុងការបង្ហាញអោយឃើញនូវទស្សនៈ របស់អ្នកគ្រប់គ្រងដែលមានចរិតគិតគូរទុកមុន នូវអ្វីដែលបំរុងនឹងអនុវត្តបន្តទៀតនៅឆ្នាំខាងមុខ ។ ការរៀបចំបែបនេះ គឺជាការជំរុញឱ្យមានការពិចារណាអំពីនិរន្តភាពយូរអង្វែងសំរាប់កិច្ចអភិវឌ្ឍន៍ ការប្រើប្រាស់ និងការពារធនធានធម្មជាតិនិងបរិស្ថាន ការរៀបចំ ការប្រើប្រាស់ និងការគ្រប់គ្រងថវិកាប្រកបដោយប្រសិទ្ធភាព ។ ម៉្យាងទៀត កម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំសង្កាត់ គឺជាឧបករណ៍សំរាប់ក្រុមប្រឹក្សាឃុំសង្កាត់ ប្រើប្រាស់ក្នុងការគ្រប់គ្រង និងដោះស្រាយរាល់បញ្ហានៅក្នុងឃុំសង្កាត់ ក្នុងភាពម្ចាស់ការមានតំលាភាព និងការទទួលខុសត្រូវខ្ពស់ ។ កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំសង្កាត់ ត្រូវរៀបរៀងជារៀងរាល់ឆ្នាំ ស្របតាមស្ថានភាពអភិវឌ្ឍន៍ជាក់ស្តែងរបស់ឃុំសង្កាត់ ។

ក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំសង្កាត់ត្រូវមានបញ្ជីគំរោងវិនិយោគ ដែលមានចែកចេញជា :

ក) តារាងគំរោងវិនិយោគឃុំសង្កាត់បីឆ្នាំរំកិល

ខ) តារាងថវិកាវិនិយោគតាមប្រភពផ្តល់

**ឧបសម្ព័ន្ធ** : គឺជាឯកសារយោង ដើម្បីរំលេចខ្លឹមសារនៃចំនុចពាក់ព័ន្ធណាមួយ អោយកាន់តែច្បាស់លាស់ និងមានមូលដ្ឋានពិតប្រាកដ ។ ហេតុនេះ ការដាក់បញ្ចូល នូវឯកសារឧបសម្ព័ន្ធនោះ អាស្រ័យទៅលើការសំរេចចិត្ត របស់ គ.ផ.ថ ។

# ផ្នែកទី២
# វិធីសាស្ត្ររៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល របស់ឃុំសង្កាត់តាមជំហាននីមួយៗ

## ជំហានទី១
## ការកំណត់បញ្ហាឬតំរូវការនៅថ្នាក់ឃុំសង្កាត់

១.១. <u>គោលបំណង</u> :

ដើម្បីអោយ គ.ផ.ថ ចាប់ផ្តើមពិនិត្យ និងពិភាក្សាកំណត់រកបញ្ហាឬតំរូវការនានា ដំណោះស្រាយ និងទីតាំងបញ្ហាឬតំរូវការនៅថ្នាក់ឃុំសង្កាត់ សំរាប់ចុះពិភាក្សាយោបល់ជាមួយអ្នកភូមិ។

១.២. <u>លទ្ធផលរំពឹងទុក</u> :

- បញ្ជី ទីតាំង បញ្ហាឬតំរូវការ មូលហេតុនិងដំណោះស្រាយ របស់ឃុំ សង្កាត់ ។
- គំនូសព្រាងផែនទីឃុំសង្កាត់ដែលមានបង្ហាញទីតាំងសំខាន់ៗនានា ។
- តំណាងភូមិពតីមាន និងមានសមត្ថភាពសំរបសំរួលនៅក្នុងការប្រជុំនៅភូមិ ។

១.៣. <u>ទីកន្លែង</u> : ថ្នាក់ឃុំ សង្កាត់

១.៤. <u>រយៈពេល</u> : គ.ផ.ថ ធ្វើការពិនិត្យនិងអនុមត្តិយករយៈពេលប្រជុំមួយដ៏សមស្រប ។

១.៥. <u>សំភារៈត្រូវការ</u> : ក្រដាសផ្ទាំងធំ ហ្វឺត ស្កត់ ផែនទី សញ្ញាសំគាល់របស់ផែនទី ឯកសារពតីមានស្ថានភាពឃុំសង្កាត់ តារាងជំនួយស្មារតី និងឧបករណ៍វិភាគផ្សេងៗទៀតដែលគាំទ្រក្នុងការរៀបចំផែនការ ដែលមានភាពរលូននិងមានគុណភាព (ប្រសិនបើមាន) ។

១.៦. <u>អ្នកចូលរួមនិងភារកិច្ច</u> :

ដើម្បីអោយការប្រជុំប្រព្រឹត្តទៅប្រកបដោយលទ្ធផលខ្ពស់ ការប្រជុំនេះត្រូវមាន : មេឃុំ ចៅសង្កាត់ជាប្រធានអង្គប្រជុំ ស្មៀនឃុំសង្កាត់ជាអ្នកកត់ត្រានិងធ្វើកំណត់ហេតុ សមាជិក គ.ផ.ថ ជាអ្នកផ្តល់យោបល់ពិភាក្សា និងអ្នកពាក់ពន្ធ័ផ្សេងៗទៀត ដូចជា សមាជិកគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឬអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ តំណាងមណ្ឌលសុខភាពឃុំភូមិ នាយកសាលាក្នុងឃុំ ..។ល។ ព្រមទាំងអ្នកសំរបសំរួល ជាអ្នកបំផុសគំនិត និងចាំបាច់ត្រូវមានតំណាងជនជាតិដើមភាគតិចចូលរួម (បើមាន) ។

១.៧. <u>ដំណើរការការងារ</u> :

**សកម្មភាព ក) ការវិភាគតាមឯកសារពតីមានឃុំសង្កាត់**

១). អ្នកសំរបសំរួល ត្រូវប្រើប្រាស់ឯកសារពតីមានស្ថានភាពឃុំសង្កាត់ជាគោល និងផែនទីឃុំសង្កាត់ដែលមានស្រាប់ ដើម្បីសំរួលដឹកនាំការពិភាក្សា និងវិភាគទៅតាមស្ថានភាពជាក់ស្តែងរបស់ឃុំសង្កាត់នីមួយៗ ។ ឃុំសង្កាត់អាចប្រើប្រាស់ពតីមានពីប្រភពផ្សេងៗបន្ថែមទៀតដូចជា មន្ទីរជំនាញ អង្គភាពអង្គការមិនមែនរដ្ឋាភិបាលឬសមាគម ...។ល។ ប្រសិនបើមានឧបករណ៍វិភាគផ្សេងៗទៀតដែលគាំទ្រដល់ការរៀបចំផែនការហើយមានភាពរលូននិងមានគុណភាព អ្នកសំរបសំរួល ក្រុមប្រឹក្សា ឃុំសង្កាត់ និងសមាជិកគ.ផ.ថ ត្រូវប្រើប្រាស់ផងដែរ ដើម្បីកំណត់ពីបញ្ហា មូលហេតុ និងដំណោះស្រាយពាក់ព័ន្ធ

នានា ។ ការអនុវត្តបែបនេះ អាចជួយឱ្យកម្មវិធីវិនិយោគឃុំសង្កាត់ កាន់តែមានលក្ខណៈគ្រប់ជ្រុងជ្រោយ ។ ករណីមានតួលេខស្ថិតិណាមួយមិនប្រក្រតី អ្នកសំរបសំរួល គួរព្យាយាមពន្យល់ទៅតំណាងភូមិអោយ ធ្វើការកត់សំគាល់ ដើម្បីរង់ចាំកែតម្រូវនៅឆ្នាំក្រោយ។ ប្រការសំខាន់នៅត្រង់ថា ប្រសិនបើកែតម្រូវ តួលេខស្ថិតិអោយត្រឹមត្រូវ តើកត្តានោះនៅតែជាបញ្ហាដូចមុនឬទេ ? បើយោងតាមស្ថានភាពជាក់ស្តែងបច្ចុប្បន្ន។

២). អង្គភាពរដ្ឋបាលមូលដ្ឋានត្រូវធ្វើកិច្ចសហការជាមួយមន្ទីរផែនការ មន្ទីរកិច្ចការនារី ខេត្តក្រុង ក្នុងការបណ្តុះបណ្តាលពង្រឹងសមត្ថភាពអ្នកសំរបសំរួលស្រុកខណ្ឌនិងខេត្តក្រុង ស្តីពីការប្រើប្រាស់វិធីសាស្ត្រវិភាគពត៌មានស្ថានភាពឃុំសង្កាត់ និងគោលការណ៍បញ្ជ្រាបយេនឌ័រ។ ឯកសារពត៌មានស្ថានភាពឃុំសង្កាត់ ជាឧបករណ៍មួយដែលជួយក្រុមប្រឹក្សាឃុំ និងគ.ផ.ថ ឱ្យដឹងពីស្ថានភាពឃុំ សង្កាត់របស់ខ្លួន និងធ្វើការវិភាគរកបញ្ហា មូលហេតុនៃបញ្ហាដែលកើតឡើងថ្មីៗ ហើយចាំបាច់ត្រូវបានដោះស្រាយ និងសមស្របទៅតាមស្ថានភាពជាក់ស្តែងរបស់ឃុំសង្កាត់ ។

៣). អ្នកសំរបសំរួលត្រូវជួយណែនាំសរសេរឃ្លាស្ថានភាពខ្លីៗជាបញ្ហា មូលហេតុ ដែលបានពីការវិភាគពត៌មានស្ថានភាពឃុំសង្កាត់ ទៅដាក់នៅលើផែនទី តាមទីតាំងជាក់ស្តែង ដើម្បីពិគ្រោះយោបល់ជាមួយសមាជិកគ.ផ.ថ ថាតើ បញ្ហាដែលកើតមានឡើងនៅតំបន់ឬភូមិនោះ ត្រូវដោះស្រាយបែបណាទើបល្អប្រសើរ។

៤). អ្នកសំរបសំរួលត្រូវពិភាក្សា និងកំណត់ផងដែរថា តើនៅលើផែនទី មានអ្វីដែលជាសក្តានុពលភាពជំនួយដល់ដំណោះស្រាយ ដូចជា សាលារៀន ផ្លូវ ស្ពាន មណ្ឌលសុខភាព ផ្សារ ប្រព័ន្ធប្រឡាយ បឹង...។ល។ វិធីបែបនេះ អាចអោយគ.ផ.ថ ងាយយល់ និងអាចធ្វើការពិចារណាបានត្រឹមត្រូវ។

៥). នៅក្នុងការពិភាក្សាកំណត់រកបញ្ហាដែលពាក់ពន្ធ័នារីនិងកុមារ នៅក្នុងជំហាននេះ គ.ផ.ថ និងអ្នកពាក់ពន្ធ័ (គណ:កម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឬអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ ឃុំសង្កាត់ តំណាងមណ្ឌលសុខភាព នាយកសាលា និងអ្នកសំរបសំរួល ) គួរតែផ្តោតលើ បញ្ហាសង្គមមួយចំនួនដូចជា ការខ្វះខាតផ្នែកអប់រំ បញ្ហាខ្វះខាតជំនាញក្នុងការប្រកបមុខរបរដល់ស្ត្រី បញ្ហានៃការផ្លាស់ប្តូរទីលំនៅ បញ្ហាខ្វះខាតផ្នែកឥណទាន បញ្ហាខ្វះខាតទឹកស្អាត បង្គន់អនាម័យ បញ្ហាទាក់ទងនឹងសុខភាពស្ត្រីនិងការខ្វះខាតផ្នែកសេវាសុខភាព បញ្ហាដែលស្ត្រីមិនបានចូលរួមក្នុងថ្នាក់ដឹកនាំភូមិនិងឃុំសង្កាត់ បញ្ហាអំពើហិង្សាក្នុងគ្រួសារ ការជួញដូរមនុស្ស ការចាប់រំលោភសេពសន្ថវ: ការប្រើប្រាស់គ្រឿងញៀន ។ល។

៦). ចំពោះឃុំសង្កាត់ដែលមានជនជាតិដើមភាគតិចរស់នៅ អ្នកសំរបសំរួលត្រូវជួយពិនិត្យមើលថាតើមានតំណាងពួកគាត់ចូលរួមដែរឬទេ? បើគ្មានអ្នកសំរបសំរួលត្រូវស្វែងរកមូលហេតុ ដែលគ្មានវត្តមានតំណាងជនជាតិដើមភាគតិច ហើយពិគ្រោះជាមួយមេឃុំសង្កាត់ថា តើការពិភាក្សាជំហាននេះគួរលើកទៅធ្វើនៅពេលក្រោយឬទេ ? ។ បើមានតំណាងជនជាតិដើមភាគតិចចូលរួម អ្នកសំរបសំរួលត្រូវរំលឹកមេឃុំ ដល់ការធានាមានការបកប្រែជាភាសាជនជាតិដើមភាគតិចទាំងនោះ ដើម្បីអោយពួកគាត់អាចយល់ពីការពិភាក្សា មានលទ្ធភាពចូលរួមយោបល់ និងព្រមព្រៀងបាន ។

**សកម្មភាព ៩) ការស្រង់បញ្ហាឬតំរូវការ**

១. ផ្អែកតាមការវិភាគខាងលើ និងបន្ទាប់ពីមានការព្រមព្រៀងលើបញ្ហាមូលហេតុ និងដំណោះស្រាយ អ្នកសំរបសំរួលត្រូវជួយណែនាំ ធ្វើការប្រមូលផ្តុំ និងកត់ត្រាយោបល់ពិភាក្សាទៅក្នុងតារាងមួយដូចមានជូនជាគំរូស្រាប់ (តារាងជំនួយស្មារតីសំរាប់ប្រើក្នុងជំហានទី១)។

**១. តារាងជំនួយស្មារតីសំរាប់ប្រើក្នុងជំហានទី១**

កត់ត្រាបញ្ហា មូលហេតុ ដំណោះស្រាយដែលបានពិភាក្សាលើផែនទី និងឯកសារស្ថានភាពឃុំសង្កាត់ ឬឧបករណ៍វិភាគផ្សេងៗ ទៀតដែលគាំទ្រក្នុងការរៀបចំផែនការ ដែលមានភាពរលូននិងមានគុណភាព ។

| បញ្ហា | ទីតាំង | ទំហំនៃបញ្ហា | មូលហេតុ | ដំណោះស្រាយ | លទ្ធភាពដោះស្រាយ |
|---|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 | 6 |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

២. ការរៀបចំតារាងនេះ គឺដើម្បីផ្តល់ភាពងាយស្រួល ក្នុងការកត់ត្រាក្នុងពេលពិភាក្សា វិភាគរកបញ្ហា មូលហេតុ ដំណោះស្រាយដែលបានពិភាក្សានិងឯកភាពនៅក្នុង គ.ផ.ថ។

<u>ក្ចូឡោនទី១</u> "បញ្ហា ឬចំណងជើងនៃបញ្ហា " អ្នកសំរបសំរួល សមាជិក គ.ផ.ថ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឬអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ អាចពិនិត្យមើលនៅលើសូចនាករនានា ដែលមាននៅក្នុងឯកសារពត៌មានស្ថានភាពឃុំសង្កាត់ ។ ប្រសិនបើគ្មានពត៌មានឬតួលេខណា ដែលបញ្ជាក់ពីឈ្មោះនៃបញ្ហា (ក្នុងឯកសារពត៌មានស្ថានភាពឃុំសង្កាត់) អ្នកសំរបសំរួលត្រូវជួយគិតណែនាំសរសេរឃ្លាខ្លីៗ ដើម្បីជាតឹកតាងបញ្ជាក់ពីបញ្ហាដែលមានកើតឡើង

ពិតប្រាកដនៅក្នុងឃុំឬភូមិ ។ អ្នកសំរបសំរួលត្រូវព្យាយាមស្វះស្វែងរកបញ្ហាឬចំណងជើងបានគ្រប់បញ្ហា ព្រោះបញ្ហាឬចំណងជើងនៃបញ្ហាទាំងនេះ គឺជាពត៌មានចាំបាច់ដែលត្រូវយកទៅសរសេររៀបរាប់ទៅតាមផ្នែកទាំងប្រាំនៅជំពូកទី១ (ការវិភាគពីស្ថានភាពឃុំសង្កាត់) នៃឯកសារកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់ឃុំ សង្កាត់ ។

<u>កូឡោនទី២</u> : ការកត់ត្រាទីតាំងដោយសរសេរឈ្មោះភូមិឬចំនុចណាមួយ ប៉ុន្តែប្រសិនបើបញ្ហាកើតមានច្រើនកន្លែងមិនអាចសរសេរអស់ សូមប្រើលេខកូដសំគាល់ជំនួសវិញ ។ ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ថា ជាតំបន់រស់នៅរបស់ជនជាតិដើមភាគតិច ប្រសិនបើឃុំសង្កាត់មានជនជាតិដើមភាគតិចរស់នៅ ។ ចំនុចសំខាន់ដែលត្រូវកត់សំគាល់ គឺឈ្មោះទីតាំងដែលកើតឡើងនូវបញ្ហាដែលចង់បាន ព្រោះបន្ទាប់ពីសង្ខេបលទ្ធផលព្រមព្រៀង តំណាងភូមិជាសមាជិក គ.ផ.ថ ត្រូវស្រង់យកបញ្ហាដែលមានជាក់ស្តែងនៅក្នុងទីតាំងភូមិនិមួយៗយកទៅធ្វើការប្រជុំពិភាក្សាបន្តនៅថ្នាក់ភូមិ។

<u>កូឡោនទី៣</u> : ត្រូវធ្វើការកត់ត្រាចូលអំពីទំហំឬកំរិតរបស់បញ្ហា ដែលមានកើតឡើងនៅតាមភូមិដោយយោងតាមពត៌មានដែលមានក្នុងឯកសារស្ថានភាពឃុំ សង្កាត់ ហើយដែលនាំគ្នាវិភាគស្វែងរកតម្រូវការដោះស្រាយ ។

<u>កូឡោនទី៤</u> : អ្នកសំរបសំរួល និង គ.ផ.ថ ត្រូវរំលេចឱ្យឃើញនូវមូលហេតុដែលនាំមកនូវបញ្ហាតាមភូមិនិមួយៗ ។ ថ្វីបើបញ្ហាកើតឡើងដូចគ្នាមែន តែហេតុផលឬមូលហេតុនៃបញ្ហាតាមភូមិនិមួយៗអាចមិនដូចគ្នាទេ ។

<u>កូឡោនទី៥</u> : ត្រូវធ្វើការកត់បញ្ចូលនូវយោបល់ជាដំណោះស្រាយដែលបានមកនៅពេលពិភាក្សា ។ តែជាដំណោះស្រាយបណ្តោះអាសន្នប៉ុណ្ណោះ ព្រោះត្រូវយកទៅធ្វើសុពលភាពជាមួយអ្នកភូមិនៅជំហានទី២ ។

<u>កូឡោនទី៦</u> : ក្នុងកូឡោនទី៦នេះ គ្រាន់តែសរសេរ " ឃុំអាចធ្វើខ្លួនឯង " ឬត្រូវការ " ជំនួយខាងក្រៅ" ដោយមិនបាច់បញ្ជាក់ដល់អ្នកពាក់ពន្ធ័ឡើយ ។ តែមុននឹងសរសេរ ក្នុងការដឹកនាំពិភាក្សាដោយក្រុមប្រឹក្សាឃុំ សង្កាត់ គ.ផ.ថ អ្នកសំរបសំរួល គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ ឬ អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ ត្រូវរួមគ្នាធ្វើការពិចារណាលើដំណោះស្រាយឬសកម្មភាព ដែលបានលើកឡើងនៅក្នុងកូឡោនទី៥ ថាតើមានដំណោះស្រាយឬសកម្មភាពណាខ្លះដែលឃុំ សង្កាត់ ឬភូមិអាចអនុវត្តបាន ដោយមិនត្រូវការចំណាយថវិកាច្រើនឬមិនចាំបាច់ត្រូវការជំនួយពីខាងក្រៅ ។

៣. សូមកត់សំគាល់ថា បញ្ហា មូលហេតុ ដំណោះស្រាយលើកឡើងនៅក្នុងជំហាននេះ គ្រាន់តែជាការចាប់ផ្តើមអោយមានការគិតគូរទៅលើបញ្ហាចំបងមួយចំនួនដែលកើតមានឡើងនៅតាមភូមិ សំរាប់ជាមូលដ្ឋានក្នុងការពិភាក្សានៅភូមិ ហើយនិងសរុបឡើងវិញនៅជំហានទី៣បន្តទៀត ។

**សកម្មភាព ៨) ការពង្រឹងសមត្ថភាពតំណាងភូមិសំរាប់អនុវត្តជំហានទី២**

១. អ្នកសំរបសំរួលត្រូវពន្យល់ដល់តំណាងភូមិពីគោលបំណង និងវិធីសាស្ត្រណែនាំការពិភាក្សាជាមួយអ្នកភូមិ និងការត្រៀមរៀបចំសំភារៈផ្សេងៗដែលចាំបាច់ ។ ត្រូវចងចាំថា គោលបំណងសំខាន់នៃការពិភាក្សានៅភូមិ គឺដើម្បីផ្តល់ឱកាសអោយប្រជាជនបញ្ចេញទស្សនៈ អំពីការអភិវឌ្ឍន៍ មូលដ្ឋានខ្លួន និងពិនិត្យស្វែងរកឬសគល់នៃបញ្ហា ព្រមទាំងលទ្ធភាពដោះស្រាយ ក៏ដូចជាលទ្ធភាពចូលរួមចំណែករបស់ប្រជាជននៅក្នុងភូមិ បើគំរោងត្រូវបានអនុវត្តក្នុងភូមិរបស់គាត់ ។

២. តំណាងភូមិនិមួយៗត្រូវស្រង់យក : បញ្ហា (ក្ខឡោនទី១) ទំហំនៃបញ្ហា (ក្ខឡោនទី៣) មូលហេតុ (ក្ខឡោនទី៤) និងដំណោះស្រាយ (ក្ខឡោនទី៥) ទៅតាមទីតាំងនៃបញ្ហាដែលពាក់ពន្ធ័នឹងភូមិរបស់ខ្លួនក្នុងតារាងជំនួយស្មារតីជំហានទី១ ទៅដាក់បញ្ចូលក្នុងក្ខឡោនទី១ ទី២ ទី៣ និងក្ខឡោនទី៤ នៃតារាងជំនួយស្មារតីទី២ឱ្យរួចជាស្រេច ដើម្បីយកទៅធ្វើសុពលភាពនៅថ្នាក់ភូមិ ។

៣. ដើម្បីអោយការប្រជុំពិភាក្សានៅថ្នាក់ភូមិបានល្អ អ្នកសំរបសំរួល គួរធ្វើការជ្រើសរើសភូមិណាមួយមកធ្វើការសាកល្បងបង្ហាញជាក់ស្តែង ដោយតំណាងភូមិណាម្នាក់ដែលមានបទពិសោធន៍ ក្រោមការសង្កេតរបស់តំណាងភូមិដទៃទៀត និងអ្នកសំរបសំរួល។ បន្ទាប់ពីធ្វើការសាកល្បង អ្នកសំរបសំរួល ត្រូវដឹកនាំពិភាក្សាទៅលើវិធីសាស្ត្រសំរបសំរួល និងកែតំរូវចំណុចខ្វះខាតផ្សេងៗ ។

៤. បន្ទាប់ពីបានសាកល្បងរួច អ្នកសំរបសំរួលត្រូវជួយតំណាងភូមិក្នុងការរៀបចំផែនការការងារឱ្យបានច្បាស់លាស់ និងរៀបចំនិងប្រគល់សំភារៈចាំបាច់មួយចំនួន ដើម្បីអាចរៀបចំការប្រជុំពិភាក្សាជាមួយអ្នកភូមិប្រកបដោយប្រសិទ្ធភាព។

# ជំហានទី២

## ការប្រជុំពិភាក្សាជាមួយប្រជាជនក្នុងភូមិ

២.១. <u>គោលបំណង</u> :

ដើម្បីអោយអ្នកភូមិពិភាក្សាស្វែងរកបញ្ហាឬតំរូវការ និងដំណោះស្រាយនៅភូមិ ។

២.២. <u>លទ្ធផលរំពឹងទុក</u> :

បញ្ជីបញ្ហា មូលហេតុ និងដំណោះស្រាយជាអាទិភាពដែលស្នើឡើងដោយអ្នកភូមិ ។

២.៣. <u>ទីកន្លែង</u> : នៅភូមិ ។

២.៤. <u>រយៈពេល</u> : តាមពេលវេលាសមស្រប ដែលប្រជាជនភាគច្រើនអាចចូលរួមបាន ។

២.៥. <u>សំភារៈត្រូវការ</u> : ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត ផែនទី តារាងជំនួយស្មារតី និងឧបករណ៍វិភាគផ្សេងៗទៀត ដែលគាំទ្រក្នុងការរៀបចំផែនការ ហើយមានភាពរលូននិងមានគុណភាព(បើមាន) ។

២.៦. <u>អ្នកចូលរួមនិងភារកិច្ច</u> :

ដើម្បីអោយការប្រជុំប្រព្រឹត្តទៅប្រកបដោយលទ្ធផលខ្ពស់ ការប្រជុំនេះ ត្រូវមានតំណាងភូមិជាសមាជិក គ.ផ.ថ ជាអ្នកសំរបសំរួលបំផុសការពិភាក្សា សមាជិកណាម្នាក់ជាអ្នកកត់ត្រា និងធ្វើកំណត់ហេតុ តំណាងអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ និងតំណាងគ្រួសារជាអ្នកផ្តល់យោបល់ (តិចបំផុត៦០%) បើមានជនជាតិដើមភាគតិចរស់នៅ ដាច់ខាតត្រូវមានតំណាងពួកគេចូលរួមផ្តល់យោបល់ឯកភាព ។

២.៧. <u>ដំណើរការការងារ</u> :

**សកម្មភាព ក) ការរៀបចំកិច្ចប្រជុំនៅភូមិ**

១. តំណាងភូមិជាសមាជិក គ.ផ.ថ ដែលបានត្រៀមខ្លួនរួចរាល់នៅជំហាន១ ត្រូវអញ្ជើញតំណាងគ្រួសារនៅក្នុងភូមិ និងភាគីពាក់ព័ន្ធក្នុងភូមិទាំងអស់ អោយមកចូលរួមប្រជុំតាមទីកន្លែង និង ពេលវេលាកំណត់ ។ តំណាងភូមិត្រូវផ្សព្វផ្សាយគោលបំណងនៃការរៀបចំការប្រជុំភូមិឱ្យបានច្បាស់លាស់ ។ សំរាប់ការប្រជុំនេះ ត្រូវព្យាយាមអញ្ជើញតំណាងគ្រួសារនីមួយៗ មកចូលរួមឱ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបាន ដើម្បីចៀសវាងការរិះគន់ និងការមិនអើពើក្នុងការចូលរួមគាំទ្រការអនុវត្តគំរោងនៅពេលក្រោយ ។

២. ចំពោះភូមិដែលមានជនជនជាតិដើមភាគតិចរស់នៅ ត្រូវមានអ្នកបកប្រែភាសា និងត្រូវជ្រើសរើសពេលវេលា និងរៀបចំសំភារៈពន្យល់ឱ្យបានសមស្របបំផុត ដើម្បីឱ្យពួកគាត់អាចយល់ និងចូលរួមពេញលេញពិតប្រាកដនៅក្នុងការពិភាក្សា ។

៣. តំណាងភូមិត្រូវរៀបចំទុកជាមុននូវតារាងបញ្ហា ទំហំនៃបញ្ហា មូលហេតុ ដំណោះស្រាយ ដែលពាក់ព័ន្ធនិងភូមិនេះ ដែលបានមកពីការពិភាក្សានៅថ្នាក់ឃុំសង្កាត់ សៀវភៅទិន្នន័យភូមិសំរាប់ជាជំនួយ ក្រដាស ផ្ទាំងធំ និងក្តារខៀន ។

៤. តំណាងភូមិត្រូវដឹកនាំការពិភាក្សាជាមួយអ្នកភូមិ និងភាគីពាក់ព័ន្ធទាំងអស់ ដោយប្រើប្រាស់ ក្តារខៀន ឧឃោសនៈស័ព្ទ (បើមាន) និងក្រដាសផ្ទាំងធំកត់ត្រាពន្យល់ និងយោបល់ពិភាក្សា ។

**សកម្មភាព ៦) ពិភាក្សាពីបញ្ហាឬតំរូវការនិងរកដំណោះស្រាយសមស្របតាមស្ថានភាពភូមិ**

១. តំណាងភូមិជាសមាជិកគ.ផ.ថ ត្រូវលើកយកនូវបញ្ហា មូលហេតុ ដំណោះស្រាយនៅក្នុងភូមិខ្លួន ដែលបានពិភាក្សានៅឃុំ សង្កាត់ ឱ្យប្រជាជននៅក្នុងភូមិដឹងថា អ្វីខ្លះដែលជាកង្វល់ឬ បំណងប្រាថ្នារបស់ឃុំសង្កាត់សំរាប់ភូមិនេះ (កូឡោនទី១ ទី២ ទី៣ និងទី៤ នៃតារាងជំនួយស្មារតីទី២)។ តំណាងភូមិជាសមាជិកគ.ផ.ថ ត្រូវស្វែងរកការបញ្ជាក់អោយបានច្បាស់លាស់ថា បញ្ហា ទំហំនៃបញ្ហា មូលហេតុឬហេតុផលទាំងនោះ ពិតជាកើតមានជាក់ស្តែងនៅក្នុងភូមិនេះមែន ហើយដំណោះស្រាយ ដែលបានលើកឡើងនៅថ្នាក់ឃុំ សង្កាត់ ពិតជាឆ្លើយតបទៅនឹងបំណង ប្រាថ្នារបស់អ្នកភូមិពិតប្រាកដ ។ នៅក្នុងការពិភាក្សានេះ អ្នកភូមិអាចទទួលយកដោយធ្វើសុពលភាពបញ្ហា ទំហំនៃបញ្ហា មូលហេតុឬហេតុផល និងដំណោះស្រាយដែលបានលើកឡើងនៅថ្នាក់ឃុំ សង្កាត់ ។ តែជាមួយនោះ ក៏អាចធ្វើការកែសំរួលទៅលើបញ្ហា ទំហំនៃបញ្ហា មូលហេតុ និងដំណោះស្រាយដែលរកឃើញនៅក្នុងជំហានទី១ ឬលុបចោលនូវបញ្ហា មូលហេតុ ឬដំណោះស្រាយណាដែលមិនសមស្រប ដែលអ្នកភូមិមិនអាចទទួលយកបាន។

២. ក្រោយពីមានការឯកភាពពីអ្នកភូមិ តំណាងភូមិជាសមាជិក គ.ផ.ថ ត្រូវបែងចែកក្រុមពិភាក្សាជាពីរក្រុមតាមភេទ ដើម្បីពិភាក្សារកបញ្ហា ទំហំនៃបញ្ហា មូលហេតុ ដំណោះស្រាយអ្វីដែលកើតមានឡើងនៅពេលថ្មីៗនេះ ឬបញ្ហាដែលនៅសេសសល់ ដែលឃុំសង្កាត់មិនទាន់បានដឹងឬមិនបានលើកឡើង ។ ការបែងចែកការពិភាក្សាជាពីរក្រុមនេះ គឺដើម្បីផ្តល់ឱកាសស្ត្រីលើកឡើងពីបញ្ហា មូលហេតុ និងដំណោះស្រាយណា ដែលមានសារៈសំខាន់ ឆ្លើយតបជាអតិបរមាដល់ស្ត្រីនិងកុមារ ។ ក្នុងកិច្ចប្រជុំក្រុមស្ត្រីនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ តំណាងភូមិជាសមាជិក គ.ផ.ថ ត្រូវលើកទឹកចិត្តនិងជំរុញឱ្យស្ត្រីបានចូលរួមប្រកបដោយអត្ថន័យ។ ម្យ៉ាងទៀត ក្រុមប្រឹក្សាឃុំសង្កាត់ សមាជិក គ.ផ.ថ ត្រូវកត់ត្រាចំនួនអ្នកចូលរួមស្ត្រី ចំនួនលើក ដែលស្ត្រីបានបញ្ចេញយោបល់ឬសំណួរ ។

៣. ក្រោយពីពិភាក្សាតាមក្រុមនិមួយៗ តំណាងភូមិជាសមាជិក គ.ផ.ថ ត្រូវយកអ្វីដែលរកឃើញថ្មីទាំងពីរក្រុម(បញ្ហា ទំហំនៃបញ្ហា មូលហេតុ និងដំណោះស្រាយ)សរសេរបញ្ចូលបន្ថែមទៅតាម

កូឡោនបញ្ហា ទំហំនៃបញ្ហា មូលហេតុ និងដំណោះស្រាយដែលអ្នកភូមិបានធ្វើសុពលភាពរួចហើយ។

៤. *កូឡោនទី៥* : ក្រោយពីដាក់បញ្ចូលគ្នាហើយ តំណាងភូមិជាសមាជិក គ.ផ.ថ ត្រូវពិភាក្សាពិចារណាជាមួយអ្នកភូមិ ដោយធ្វើការគូសសញ្ញា(✓)ជាសំគាល់និងធ្វើការកត់សំគាល់(សរសេរឃ្លាខ្លីៗ)ទៅលើ :

- ដំណោះស្រាយណាខ្លះដែលឆ្លើយតបទៅនឹងតម្រូវការឬបញ្ហាជាក់លាក់ដល់ស្ត្រីនិងកុមារ
- ដំណោះស្រាយដែលផ្តល់ផលប្រយោជន៍ភាគច្រើនដល់ស្ត្រីនិងកុមារ

ការឆ្លើយតបទៅនឹងតម្រូវការឬបញ្ហាជាក់លាក់ ឬផ្តល់ផលប្រយោជន៍ភាគច្រើនដល់ស្ត្រីនិងកុមារ រួមមាន : ការជួយលើកកំពស់សិទ្ធិស្ត្រី ការលុបបំបាត់ភាពរើសអើងលើស្ត្រី ការលើកកំពស់តួនាទី ឋានៈស្ត្រី ការបង្កើនចំណេះដឹងនិងជំនាញ ការធានាសុវត្ថិភាពដល់ស្ត្រីនិងកុមារ ។

៥. ក្នុងការចាត់អាទិភាព(*កូឡោនទី៦*) តំណាងភូមិជាសមាជិក គ.ផ.ថ ត្រូវពិភាក្សាដើម្បីស្វែងរកការព្រមព្រៀងជាមួយអ្នកភូមិថា តើក្នុងចំណោមដំណោះស្រាយដែលបានលើកឡើង តើមួយណាដែលជាអាទិភាព "ខ្ពស់" "មធ្យម" និង "ទាប" ។

៦. ដើម្បីចាត់លំដាប់អាទិភាពបានត្រឹមត្រូវ តំណាងភូមិជាសមាជិក គ.ផ.ថ អាចប្រើប្រាស់វិធីសាស្ត្រមួយចំនួនដូចតទៅ :

- ម៉ាទ្រីចឬការប្រៀបធៀបគូ
- ការបោះឆ្នោត
- ការពិភាក្សានិងព្រមព្រៀងមតិ

៧. *កូឡោនទី៧* "លទ្ធភាពចូលរួម " តំណាងភូមិជាសមាជិក គ.ផ.ថ ដែលដឹកនាំការប្រជុំពិភាក្សានៅថ្នាក់ភូមិ ធ្វើការពិភាក្សាជាមួយអ្នកភូមិ ដោយពិចារណាពីលទ្ធភាពចូលរួមរបស់អ្នកភូមិលើដំណោះស្រាយឬសកម្មភាពដែលបានស្នើឡើង ប្រសិនបើដំណោះស្រាយឬសកម្មភាពទាំងនោះត្រូវបានអនុវត្ត ។ លទ្ធភាពចូលរួមនេះ គ្រាន់តែជាការពន្យាក់ឬបណ្តុះស្មារតីដល់អ្នកភូមិឱ្យដឹងថាប្រសិនបើរាល់ដំណោះស្រាយដែលស្នើឡើងត្រូវបានអនុវត្ត នោះទៀមទារឱ្យមានការចូលរួមពីអ្នកភូមិ ។ លទ្ធភាពនៃការចូលរួមនេះ អាចជាទុនបដិភាគ ជាកំលាំងពលកម្ម .... ។ល។ ប្រសិនបើអ្នកភូមិពិចារណាថា គ្មានលទ្ធភាពចូលរួមអ្វីសោះនោះ សូមសរសេរថា " គ្មាន " ។ ចំពោះ *កូឡោនទី៨* "យោបល់ឯកភាពរបស់ជនជាតិដើមភាគតិច " ប្រើសំរាប់តែឃុំសង្កាត់ណា ដែលមានជនជាតិដើមភាគតិចរស់នៅ ដើម្បីកត់ត្រាពីអ្វីដែលក្រុមជនជាតិដើមភាគតិចបានឯកភាពឬជំទាស់ បើឃុំសង្កាត់ណាគ្មានជនជាតិដើមភាគតិចរស់នៅ មិនបាច់គូសកូឡោននេះឡើយ ។

៨. ប្រសិនបើមានឧបករណ៍វិភាគផ្សេងៗទៀតដែលគាំទ្រក្នុងការរៀបចំផែនការហើយមានភាពរលូន និងមានគុណភាព តំណាងភូមិជាសមាជិក គ.ជ.ថ ត្រូវប្រើប្រាស់ផងដែរ ដើម្បីកំណត់ពីបញ្ហា មូលហេតុ និងដំណោះស្រាយពាក់ព័ន្ធនានា ។ ការអនុវត្តបែបនេះ អាចជួយអោយកម្មវិធីវិនិយោគឃុំសង្កាត់ កាន់តែមានលក្ខណៈគ្រប់ជ្រុងជ្រោយ ។

៩. ប្រសិនបើមានផែនការអភិវឌ្ឍន៍ភូមិ បានរៀបចំរួចហើយ នោះរាល់សកម្មភាពគ្រោងក្នុងផែនការនោះ អាចចាត់ទុកថាជាដំណោះស្រាយដែលបានស្នើឡើងដោយអ្នកភូមិ សំរាប់បញ្ចូលទៅក្នុងកម្មវិធីវិនិយោគឃុំសង្កាត់ ប៉ុន្តែត្រូវមានការពិភាក្សាជាមួយអ្នកភូមិ ឬសហគមន៍ថែមទៀត ដើម្បីបញ្ជាក់ពីការឯកភាពយល់ព្រម ។

១០. តំណាងភូមិជាសមាជិកគ.ជ.ថ ត្រូវបង្កើតបរិយាកាសពិភាក្សាប្រកបដោយភាពស្និទ្ធស្នាល និងយោគយល់ទៅវិញទៅមក ហើយត្រូវចៀសវាងការឈ្លោះប្រកែក ឬការប្រើប្រាស់វេទិកាប្រជុំ ភូមិដើម្បីដោះស្រាយបញ្ហាបុគ្គល ឬដើម្បីបំរើអោយគណបក្សនយោបាយ។ គោលបំណងសំខាន់នៃការប្រជុំភូមិនេះ គឺដើម្បីពិភាក្សាពីកិច្ចអភិវឌ្ឍន៍មូលដ្ឋាន។

១១. ដើម្បីឱ្យការប្រជុំភូមិប្រព្រឹត្តទៅបានលទ្ធផលល្អប្រសើរ តំណាងភូមិជាសមាជិក គ.ជ.ថ គួរ ចាប់អារម្មណ៍លើចំណុចមួយចំនួនដូចខាងក្រោម :

- ធ្វើការផ្សព្វផ្សាយអោយបានយ៉ាងហោច២ថ្ងៃមុនពេលប្រជុំ ។
- រៀបចំកន្លែងអង្គុយយ៉ាងណាអោយអ្នកចូលរួមអាចមើលឃើញនិងស្តាប់គ្នាពូទៅវិញទៅមក។
- ជ្រើសរើសពេលវេលាសមស្រប សម្រាប់អ្នកភូមិ ជាពិសេសស្ត្រី។
- ប្រើក្រដាសផ្ទាំងធំ ដើម្បីសរសេរអក្សរធំៗ មានលាយពណ៌ខុសៗគ្នា ឬប្រើគំនូសតាង ឬនិមិត្តសញ្ញាងាយៗ ។

## ២. តារាងជំនួយស្មារតីសំរាប់ប្រើក្នុងជំហានទី២

ការកត់ត្រាលទ្ធផលពិភាក្សានៅភូមិ ............ សំរាប់យកមកពិភាក្សាបន្តនៅថ្នាក់ឃុំសង្កាត់

| បញ្ហា | ទំហំនៃបញ្ហា | មូលហេតុ | ដំណោះស្រាយស្នើឡើងដោយអ្នកភូមិ | ដំណោះស្រាយដែលឆ្លើយតបដល់នារីនិងកុមារ | អាទិភាព | លទ្ធភាពចូលរួម | យោបល់ឯកភាពរបស់ជនជាតិដើមភាគតិច |
|---|---|---|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

*<u>សំគាល់</u> : ក្ឡោនទី៨ ត្រូវគូសបន្ថែមតែឃុំសង្កាត់ណា ដែលមានជនជាតិដើមភាគតិចរស់នៅ ។*

## ជំហានទី៣

## ការប្រជុំកំណត់បញ្ហាឬគំរូចការនៅឃុំសង្កាត់

៣.១. <u>គោលបំណង</u> :

ដើម្បីស្រង់យកដំណោះស្រាយ ដែលបានស្នើឡើងដោយអ្នកភូមិ យកមកបញ្ចូលជាមួយដំណោះស្រាយដែលបានរកឃើញនៅថ្នាក់ឃុំសង្កាត់ ទៅតាមផ្នែកទាំង៥ និងចាត់អាទិភាព ។

៣.២. <u>លទ្ធផលរំពឹងទុក</u> :

បញ្ជីដំណោះស្រាយចុងក្រោយដែល គ.ផ.ថ សំរេចទទួលយកជាអាទិភាព និងគោលបំណងនៃដំណោះស្រាយ ។

៣.៣. <u>ទីកន្លែង</u> : នៅឃុំ សង្កាត់ ។

៣.៤. <u>រយៈពេល</u> : អាស្រ័យតាមការកំណត់របស់ គ.ផ.ថ ។

៣.៥. <u>សំភារៈត្រូវការ</u> : ក្រដាសផ្ទាំងធំ ហ្វឺត ស្កត់ ផែនទី ម៉ាស៊ីនគិតលេខ តារាងជំនួយស្មារតីនៃលទ្ធផលជំហានទី១ និងជំហានទី២ ។

៣.៦. <u>អ្នកចូលរួមនិងភារកិច្ច</u> :

ដើម្បីអោយការប្រជុំប្រព្រឹត្តទៅប្រកបដោយលទ្ធផលខ្ពស់ ការប្រជុំនេះ ត្រូវមាន មេឃុំ ចៅសង្កាត់ជាប្រធានអង្គប្រជុំ ស្មៀនឃុំសង្កាត់ជាអ្នកកត់ត្រានិងធ្វើកំណត់ហេតុ សមាជិកគ.ផ.ថ ជាអ្នករាយការណ៍ពិភាក្សានិងព្រមព្រៀងនិងអ្នកពាក់ពន្ធ័ ដូចជា គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ ឬអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារជាអ្នកផ្តល់យោបល់ អ្នកសំរបសំរួលជាអ្នកសំរបសំរួលការពិភាក្សា និងចាំបាច់ត្រូវមានតំណាងជនជាតិដើមភាគតិចចូលរួមឯកភាព (បើមាន) ។

៣.៧. <u>ដំណើរការការងារ</u> :

**សកម្មភាព ក) បូកសរុបដំណោះស្រាយស្នើឡើងដោយអ្នកភូមិនិងគ.ផ.ថ**

១. ដើម្បីងាយស្រួល អ្នកសំរបសំរួលត្រូវប្រើក្រដាសមួយផ្ទាំង សំរាប់មួយផ្នែក ហើយបង្ហាញតែកូឡោនទី១ ទី២ និងទី៣ សិន ។ *សូមកុំព្យាយាមបង្ហាញកូឡោនទី៤ ទី៥ ទី៦ និងទី៧ ក្នុងពេលតែមួយ* ព្រោះវាអាចឱ្យតំណាងភូមិជាសមាជិកគ.ផ.ថ ផ្តោតលើកូឡោននេះ ដោយភ្លេចពិចារណាពីអត្ថន័យ និងអត្ថប្រយោជន៍របស់ឃ្លាដំណោះស្រាយ ដែលតំណាងភូមិជា សមាជិក គ.ផ.ថ និមួយៗលើកឡើង ។

២. តំណាងភូមិដំបូងត្រូវរាយការណ៍ពីដំណោះស្រាយជាអាទិភាពក្នុងផ្នែកទាំងប្រាំ (ដោយប្រើ "ខ" សំរាប់សំគាល់អាទិភាព"ខ្ពស់" "ម" សំរាប់សំគាល់អាទិភាព "មធ្យម" និង"ទ" សំរាប់ សំគាល់អាទិភាព"ទាប") តាមទំរង់តារាងជំនួយស្មារតីទី៣.១ (សូមពិនិត្យគំរូ) ។

៣. អ្នកសំរបសំរួលត្រូវជួយ គ.ផ.ថ ក្នុងការពិនិត្យទៅលើអត្ថប្រយោជន៍នៃដំណោះស្រាយ តើដំណោះស្រាយទាំងនោះ ឆ្លើយតបទៅនឹងមុខសញ្ញាផ្នែកណាមួយ ។ តាមធម្មតា ដំណោះស្រាយមួយតែងបំរើផលប្រយោជន៍ច្រើនផ្នែក ឬចំរុះផ្នែក ហេតុនេះអ្នកសំរបសំរួលគួរពិចារណាពីទំងន់នៃអត្ថប្រយោជន៍នោះ ថាតើវាគួរស្ថិតក្នុងផ្នែកណាមួយ ។ ឧទាហរណ៍ : ដំណោះស្រាយផ្តល់ឥណទានដើម្បីជួយដល់ស្ត្រីក្រីក្រ ស្ត្រីមេម៉ាយ និងស្ត្រី ជាមេគ្រួសារមានកូនតូចជាង៥ឆ្នាំ ។ បើគិតពីឥណទានវាត្រូវនៅក្នុងផ្នែកសេដ្ឋកិច្ច ប៉ុន្តែបើគិតពីមុខសញ្ញាគឺផ្តល់ទំងន់ទៅលើផ្នែកយេនឌ័រ ហេតុនេះដំណោះស្រាយត្រូវសរសេរក្នុងផ្នែកយេនឌ័រ ។

៤. តំណាងភូមិបន្ទាប់រាយការណ៍ពីដំណោះស្រាយជាអាទិភាពដូចភូមិមុនៗដែរ ។ ក្នុងករណីដំណោះស្រាយមានភាពស្រដៀងគ្នា អ្នកសំរបសំរួលត្រូវ បញ្ជាក់ពីអត្ថន័យអោយច្បាស់លាស់ដើម្បីអោយតំណាងភូមិបន្ទាប់ ទទួលយល់ស្របតាមឃ្លាតំណាងភូមិមុនៗ ។ ការធ្វើបែបនេះ គឺដើម្បីកុំអោយមានការសរសេរឃ្លាដំណោះស្រាយដដែលៗជាន់គ្នា ។

៥. អ្នកសំរបសំរួល អាចប្រើវិធីម៉្យាងទៀត ដោយអានឃ្លាដំណោះស្រាយដែលតំណាងភូមិដំបូងលើកឡើងនិងបានកត់ត្រារួច បន្ទាប់មកសួរទៅតំណាងភូមិបន្តបន្ទាប់ ថាតើប្រជាជនក្នុងភូមិ នោះមានស្នើឡើងនូវដំណោះស្រាយបែបនេះ ឬស្រដៀងនេះដែរឬទេនៅក្នុងភូមិខ្លួន បើមាន តើវាជាអាទិភាព "ខ្ពស់" "មធ្យម" ឬ "ទាប" ដែលត្រូវកត់ត្រាក្នុងកូឡោនទី៣ ។ បើមានដំណោះស្រាយផ្សេងទៀតមិនទាន់កត់ត្រា ត្រូវកត់ត្រាបន្ថែម ។

## ៣.១ តារាងជំនួយស្មារតីសំរាប់ប្រើក្នុងជំហានទី៣

*សំរង់ដំណោះស្រាយបានពិភាក្សាទាំងអស់ ដើម្បីពិនិត្យមើលពីភាពស្របគំនិតនិងភាពចាំបាច់*

| ល.រ | ដំណោះស្រាយស្នើឡើង | អាទិភាពស្រង់ចេញពីតារាងភូមិ | | | | | ពិន្ទុសំរាប់ពិចារណា | | | | អាទិភាពសំរេច |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ក | ខ | គ | ឃ | ... | ទូទាំងឃុំ | តំលៃយេនឌ័រ | ចាំបាច់ | ពិន្ទុសរុប | |
| 1 | 2 | 3 | | | | | 4 | 5 | 6 | 7=4+5+6 | 8 |
| សេដ្ឋកិច្ច | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| សង្គមកិច្ច | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| ធនធានធម្មជាតិនិងបរិស្ថាន | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| សេវាកម្មរដ្ឋបាលនិងសន្តិសុខ | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| យេនឌ័រ | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |

## សកម្មភាព ៦) ការដាក់អាទិភាពដំណោះស្រាយ

១. អ្នកសំរបសំរួល ត្រូវគូសបន្ថែម កូឡោនទី៤ ទី៥ ទី៦ និងកូឡោនទី៧ (បើមិនទាន់គូស) ។

២. នៅក្នុងកូឡោនទី៤ បូកពិន្ទុអាទិភាពតាមភូមិ (កូឡោនទី៣) ដោយកំណត់ថា : "ខ=៣" "ម=២" "ទ=១" បន្ទាប់មកចែកពិន្ទុសរុបជាមួយនឹងចំនួនភូមិដែលមាននៅក្នុងឃុំសង្កាត់ ដើម្បីរកពិន្ទុមធ្យម ចុះក្នុងកូឡោនទី៤ ។

៣. កូឡោនទី៥ : គ.ផ.ថ ត្រូវធ្វើការពិភាក្សាដាក់ពិន្ទុពីតំលៃយេនឌ័រ ទៅលើដំណោះស្រាយនិមួយៗដូចខាងក្រោម :

- ដំណោះស្រាយដែលមិនឆ្លើយតបស្ត្រីនិងកុមារ = ១ពិន្ទុ
- ដំណោះស្រាយដែលឆ្លើយតបភាគច្រើននិងជាក់លាក់ដល់ស្ត្រីនិងកុមារអាចមានពិន្ទុ៣ ឬពិន្ទុ ២

មានន័យថា ដំណោះស្រាយណាដែលមិនបានគូសសញ្ញា(✓) ដោយអ្នកភូមិនៅក្នុងជំហានទី២ ត្រូវបាន១ពិន្ទុ ចំពោះដំណោះស្រាយណាដែលបានគូសសញ្ញា(✓) ត្រូវធ្វើការពិចារណា ដើម្បីដាក់ ពិន្ទុ ២ ឬពិន្ទុ ៣ ។ ដើម្បីឱ្យការដាក់ពិន្ទុ២ឬ៣ទៅលើដំណោះស្រាយដែលបានគូសសញ្ញា(✓) បានត្រឹមត្រូវ អ្នកសំរបសំរួលត្រូវជួយ គ.ផ.ថ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ ឬអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ ដោយប្រើតារាងវិភាគនិងវាយតំលៃលើដំណោះស្រាយដែលឆ្លើយតបស្ត្រីនិងកុមារ ដូចខាងក្រោម :

**តារាងវិភាគនិងវាយតំលៃលើដំណោះស្រាយដែលឆ្លើយតបស្ត្រីនិងកុមារថ្នាក់ឃុំសង្កាត់**

| ដំណោះស្រាយដែលឆ្លើយតបស្ត្រីនិងកុមារ | អំណះអំណាងពីភូមិលើដំណោះស្រាយ | យោបល់នៃការកំណត់តំលៃយេនឌ័ររបស់គ.ផ.ថ | ពិន្ទុតំលៃយេនឌ័រ |
|---|---|---|---|
| 1 | 2 | 3 | 4 |
| សេដ្ឋកិច្ច | | | |
| | | | |
| | | | |
| | | | |
| សង្គមកិច្ច | | | |
| | | | |
| | | | |
| ធនធានធម្មជាតិនិងបរិស្ថាន | | | |
| | | | |
| | | | |
| សេវាកម្មរដ្ឋបាលនិងសន្តិសុខ | | | |
| | | | |
| | | | |
| យេនឌ័រ | | | |
| | | | |
| | | | |

*ក្ដុឡោនទី១* : ស្រង់ដំណោះស្រាយណាដែលមានគូសសញ្ញា(✓)ដោយអ្នកភូមិនៅតាមភូមិនីមួយៗ នៅក្នុងជំហានទី២ ដាក់បញ្ចូលទៅតាមផ្នែកទាំងប្រាំ ។

*ក្ដុឡោនទី២* : ស្រង់អំណះអំណាងនៃដំណោះស្រាយដែលបានធ្វើការកត់សំគាល់ដោយអ្នកភូមិ នៅក្នុងជំហានទី២ ។ ក្នុងការស្រង់នូវអំណះអំណាងនេះ អ្នកសំរបសំរួលត្រូវជួយ គ.ផ.ថ ក្នុងការសរសេរសង្ខេបឃ្លាប្រយោគខ្លីៗ ដោយបញ្ជាក់ពីអត្ថន័យឱ្យច្បាស់លាស់ ទៅលើអំណះអំណាងនៃដំណោះស្រាយដែលអ្នកភូមិបានធ្វើការកត់សំគាល់ ។ ការធ្វើបែបនេះ គឺដើម្បីកុំឱ្យមានសរសេរឃ្លាអំណះអំណាងនៃដំណោះស្រាយដដែលៗជាន់គ្នា ថ្វីបើដំណោះស្រាយតាមភូមិនិមួយៗដូចគ្នា តែអំណះអំណាងដែលធ្វើការកត់សំគាល់ដោយអ្នកភូមិតាមភូមិនិមួយៗអាចមិនដូចគ្នា ។

*ក្ដុឡោនទី៣* : គ.ផ.ថ ត្រូវធ្វើការពិភាក្សានិងបញ្ជាក់ពីយោបល់ក្នុងការឱ្យតំលៃយេនឌ័រ ដើម្បីឈានទៅធ្វើការសំរេចចិត្តដាក់ពិន្ទុ២ឬ៣ទៅតាមផ្នែកនិមួយៗ នៅក្នុង *ក្ដុឡោនទី៤* ។ ដើម្បីជាជំនួយក្នុងការបញ្ជាក់ពីយោបល់នៃការកំណត់តំលៃយេនឌ័រ គ.ផ.ថ ត្រូវប្រើប្រាស់សំណួរតាមផ្នែកនីមួយៗដូចខាងក្រោម :

- ក្នុងផ្នែកសេដ្ឋកិច្ច : តើដំណោះស្រាយទាំងនោះបានឆ្លើយតបជាក់លាក់ឬភាគច្រើនទៅនឹងការលើកកំពស់ជីវភាពនិងតួនាទីសំរាប់ស្ត្រីដែរឬទេ? (បង្កើនប្រាក់ចំណូល សន្តិសុខស្បៀង ឥណទាន មុខជំនាញ ។ល។)
- ក្នុងផ្នែកសង្គមកិច្ច : តើដំណោះស្រាយទាំងនោះបានឆ្លើយតបជាក់លាក់ ឬភាគច្រើនបានផ្ដោតលើការផ្ដល់សេវាសង្គមសំរាប់ស្ត្រី និងកុមារដែរឬទេ ? (សុខភាព ទឹកស្អាត ការអប់រំ ។ល។)
- ក្នុងផ្នែកធនធានធម្មជាតិនិងបរិស្ថាន : តើដំណោះស្រាយទាំងនេះបានឆ្លើយតបជាក់លាក់ឬភាគច្រើនទៅនឹងតម្រូវការរបស់ស្ត្រី នៅក្នុងការប្រើប្រាស់ និងការពារធនធានធម្មជាតិនិងបរិស្ថានដែរឬទេ? (ឱកាសក្នុងការគ្រប់គ្រង និងប្រើប្រាស់អនុផលព្រៃឈើ ។ល។)
- ក្នុងផ្នែកសេវាកម្មរដ្ឋបាលនិងសន្តិសុខ : តើដំណោះស្រាយទាំងនោះបានឆ្លើយតបជាក់លាក់ ឬភាគច្រើនទៅនឹងបញ្ហាសន្តិសុខ និងសុវត្ថិភាពរបស់ស្ត្រីនិងកុមារដែរឬទេ ? ដូចជាការទប់ស្កាត់ហិង្សាក្នុងគ្រួសារ ការរំលោភផ្លូវភេទ ការជួញដូរស្ត្រីនិងកុមារ ការប្រើប្រាស់គ្រឿងញៀន។ល។
- ក្នុងផ្នែកយេនឌ័រ : តើដំណោះស្រាយទាំងនោះបានឆ្លើយតបជាក់លាក់ឬភាគច្រើនបានយកចិត្តទុកដាក់ក្នុងការលើកកំពស់សមភាពយេនឌ័រដែរឬទេ ? ដូចជា ការបង្កើនតួនាទីស្ត្រី

បង្កើនភាពអង់អាចស្ត្រី បណ្តាញការងារស្ត្រីនិងកុមារ លប់បំបាត់ភាពរើសអើងលើស្ត្រី និង កុមារ ។ល។

៤. ចំពោះកូឡោនទី៦នៃតារាង៣.១វិញ អ្នកសំរបសំរួលត្រូវដឹកនាំ គ.ផ.ថ ពិភាក្សា ដើម្បីដាក់ពិន្ទុទៅលើភាពចាំបាច់នៃដំណោះស្រាយ "ចាំបាច់ណាស់=៣" "ចាំបាច់បង្គួរ=២" "មិនសូវចាំបាច់=១" ។ ដើម្បីអោយការសំរេចដាក់ពិន្ទុនៅក្នុងកូឡោននេះបានត្រឹមត្រូវ អ្នកសំរបសំរួល គួរពិភាក្សា ជាមួយ គ.ផ.ថ ដោយប្រើលក្ខណ:វិនិច្ឆ័យមួយចំនួនដូចខាងក្រោម:

- "ចាំបាច់ណាស់" មានន័យថា :
  - □ សមាជិក គ.ផ.ថ ភាគច្រើនយល់ស្រប ដោយឈរលើមូលដ្ឋានជួយអោយមានតុល្យភាពក្នុងកិច្ចអភិវឌ្ឍន៍ឃុំសង្កាត់ ។
  - □ ជាបញ្ហាពាក់ព័ន្ធច្រើនវិស័យ ដូចជាបរិស្ថាន យេនឌ័រ សន្តិសុខ...។ល។
  - □ មានលក្ខណ:បន្ទាន់ ដែលត្រូវដោះស្រាយមុនគេ ។
- "ចាំបាច់បង្គួរ" មានន័យថា:
  - □ បំពេញលក្ខណ:វិនិច្ឆ័យខាងលើបានខ្លះៗ ។
- "មិនសូវចាំបាច់" មានន័យថា:
  - □ មិនអាចបំពេញបានតាមលក្ខណ:វិនិច្ឆ័យខាងលើទាំងស្រុង ។

៥. កូឡោនទី៧គឺជាផលបូកពិន្ទុក្នុងកូឡោន ទី៤ ទី៥និងកូឡោនទី៦ ដើម្បីចាត់អាទិភាពម្តងទៀត ។ របៀបបែងចែកជាអាទិភាពតាមពិន្ទុសរុប នៅក្នុងផ្នែកនិមួយៗនៃផ្នែកទាំង៥ អាចធ្វើតាមវិធីដូចខាងក្រោម :

✓ **របៀបទី១:** ចំណាត់ថ្នាក់អាទិភាព ខ្ពស់ មធ្យម ទាប ដោយចែកជាចន្លោះ ១ភាគ៣ អាទិភាព "ខ្ពស់" ១ភាគ៣ អាទិភាព "មធ្យម" និង១ភាគ៣ទៀត "ទាប" ។ ដើម្បីគិតតាមបែបនេះបាន អ្នកសំរបសំរួលត្រូវជួយចែកចំនួនដំណោះស្រាយសរុបក្នុងផ្នែកនិមួយៗទៅនឹង៣ ដើម្បីអោយដឹងថា ក្នុងចន្លោះអាទិភាព"ខ្ពស់" "មធ្យម" "ទាប" និមួយៗមានដំណោះស្រាយចំនួនប៉ុន្មាន ។ បន្ទាប់មកបង់លេខ១ ចំពោះដំណោះស្រាយណាដែលមានពិន្ទុខ្ពស់ជាងគេ បន្ទាប់មកលេខ២ ចំពោះពិន្ទុបន្ទាប់រៀងគ្នារហូតដល់ពិន្ទុទាបបំផុត។ ឧទាហរណ៍ ដំណោះស្រាយក្នុងផ្នែកយេនឌ័រមានសរុប១០ បើចែកនឹងបី យើងបានគំរោងមានអាទិភាព"ខ្ពស់"៣គំរោង "មធ្យម"៣គំរោង និង"ទាប"មាន៣គំរោង ។ តាមឧទាហរណ៍នេះ មានដំណោះស្រាយមួយដែលនៅសល់ ដំណោះស្រាយសល់នេះ អាចចូលទៅក្នុងនៅចំណោមអាទិភាព "ខ្ពស់" "មធ្យម" "ទាប"ទៅតាមពិន្ទុស្មើគ្នា ។ ដោយសារតែដំណោះ ស្រាយអាចមានពិន្ទុស្មើគ្នា ចំណាត់ថ្នាក់ត្រូវតែដូចគ្នា ។

✓ **របៀបទី២**: នៅក្នុងផ្នែកនិមួយៗអ្នកសំរបសំរួលត្រូវជួយយកពិន្ទុខ្ពស់បំផុត ដកពិន្ទុទាបបំផុត ហើយយកផលសងនោះទៅចែកនឹង៣ ។ បន្ទាប់មក ត្រូវយកផលចែកទៅ *បូក* ជាមួយពិន្ទុទាបបំផុត នោះនឹងបានតំលៃពិន្ទុចន្លោះកណ្តាលនៃដំណោះស្រាយមានអាទិភាព "ទាប" និង "មធ្យម" ដែលសន្មត់ហៅថា "**ពិន្ទុកំរិតចន្លោះទី១**" ។ បន្ទាប់មកទៀត ត្រូវយកពិន្ទុខ្ពស់បំផុតទៅ *ដក* តំលៃផលចែកវិញម្តង នោះនឹងទទួលបានពិន្ទុចន្លោះកណ្តាលនៃដំណោះស្រាយមានអាទិភាព "មធ្យម" និង "ខ្ពស់" ដែលហៅថា "**ពិន្ទុកំរិតចន្លោះទី២**" ។ ក្នុងការធ្វើសន្និដ្ឋាន ដំណោះស្រាយណាដែលមានពិន្ទុសរុបទាបជាងពិន្ទុកំរិតចន្លោះទី១ ត្រូវចាត់ចូលជាប្រភេទអាទិភាព "ទាប" ដំណោះស្រាយណាដែលមានពិន្ទុសរុបស្ថិតនៅចន្លោះឬស្មើពិន្ទុកំរិតចន្លោះទី១ និងពិន្ទុកំរិតចន្លោះទី២ ត្រូវចាត់ចូលជាអាទិភាព "មធ្យម" រីឯដំណោះស្រាយណាដែលមានពិន្ទុសរុបខ្ពស់ជាង ឬស្មើពិន្ទុកំរិតចន្លោះទី២ ត្រូវស្ថិតក្នុងលំដាប់អាទិភាព "ខ្ពស់" ។




*រូបភាពទី១*: វិធីបត់ខ្សែ ពន្យល់ពីពិន្ទុកំរិតចន្លោះទី១ និងពិន្ទុកំរិតចន្លោះទី២ ។

៦. អ្នកសំរបសំរួល គួរព្យាយាមពន្យល់ គ.ជ.ថ អោយប្រើប្រាស់របៀបណាមួយ ក្នុងរបៀបចាត់អាទិភាពទាំង២នេះ ដើម្បីអោយការចាត់អាទិភាពមានលក្ខណៈបច្ចេកទេសជាក់លាក់ ។

**សកម្មភាព ១ គ) ការស្រង់ដំណោះស្រាយតាមលំដាប់អាទិភាពនិងកំណត់គោលបំណង**

១. រាល់ដំណោះស្រាយ ត្រូវស្រង់ឡើងតាមលំដាប់លំដោយអាទិភាព"ខ្ពស់" "មធ្យម" និង"ទាប" ដោយដាក់លេខរៀងតាមផ្នែកទាំង៥ ។

២. បន្ទាប់ពីស្រង់ដំណោះស្រាយតាមលំដាប់អាទិភាពរួចហើយ អ្នកសំរបសំរួល ត្រូវបន្តជួយ គ.ជ.ថ ដឹកនាំពិភាក្សា ថាតើដំណោះស្រាយទាំងនោះ ស្មើឡើងក្នុងគោលបំណងអ្វី ដោះស្រាយបញ្ហាអ្វី ឬតំរូវការអ្វី ដូចបានពិចារណារួចខ្លះមកហើយក្នុងជំហានទី១ និងជំហានទី២ឬទេ ? ។ ការពិភាក្សានេះ គឺសំដៅធ្វើការកែសំរួលឃ្លាប្រយោគអោយងាយស្រួលយល់ សំរាប់បញ្ចូលទៅក្នុងកូឡោនទី៤នៃតារាងជំនួយស្មារតី ទី៣.២ ។

៣. ផលប្រយោជន៍សំខាន់នៃការកែសំរួលឃ្លានៅតាមផ្នែកនិមួយៗ គឺដើម្បីផ្តល់ភាពងាយស្រួលក្នុងការសរសេរជាឃ្លាទិសដៅ និងយុទ្ធសាស្ត្រ (ជំហានទី៤) អោយស៊ីសង្វាក់គ្នាជាមួយសកម្មភាព ដែលស្របតាមដំណោះស្រាយស្នើឡើងដោយអ្នកភូមិ និងឃុំសង្កាត់ ។

៤. ដើម្បីឈានទៅសរសេរ ជាឃ្លាទិសដៅនិងយុទ្ធសាស្ត្រដែលឆ្លើយតបនឹងយេនឌ័រ អ្នកសំរបសំរួល ត្រូវជួយសមាជិកគ.ជ.ថ សរសេរបំពេញក្នុងកូឡោនទី៤ (តារាងជំនួយស្មារតី៣.២) អោយមានអត្ថន័យច្បាស់លាស់ ដោយពិនិត្យមើលតើដំណោះស្រាយណាខ្លះដែលស្នើឡើងក្នុងគោលបំណងដោះស្រាយបញ្ហាស្ត្រីនិងកុមារ ដោយប្រើប្រាស់លទ្ធផលនៃតារាងវិភាគនិងវាយតំលៃលើ ដំណោះស្រាយដែលឆ្លើយតបស្ត្រីនិងកុមារថ្នាក់ឃុំសង្កាត់ ជាជំនួយ ។

## ៣.២ តារាងជំនួយស្មារតីសំរាប់ប្រើក្នុងជំហានទី៣

សំរង់ដំណោះស្រាយដែលរួមចំណែកសំរេចបាននូវទិសដៅនិងយុទ្ធសាស្រ្តអភិវឌ្ឍន៍

| ល.រ | ដំណោះស្រាយឃុំសង្កាត់ | អាទិភាព | ក្នុងគោលបំណង | យោបល់ឯកភាពរបស់ជនជាតិដើមភាគតិច |
|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 |
| **ផ្នែកសេដ្ឋកិច្ច** | | | | |
| 1 | | | | |
| 2 | | | | |
| | | | | |
| **ផ្នែកសង្គមកិច្ច** | | | | |
| 1 | | | | |
| 2 | | | | |
| | | | | |
| **ផ្នែកធនធានធម្មជាតិនិងបរិស្ថាន** | | | | |
| 1 | | | | |
| 2 | | | | |
| | | | | |
| **ផ្នែកសេវាកម្មរដ្ឋបាលនិងសន្តិសុខ** | | | | |
| 1 | | | | |
| 2 | | | | |
| | | | | |
| **ផ្នែកយេនឌ័រ** | | | | |
| 1 | | | | |
| 2 | | | | |
| | | | | |

*សំគាល់ : ក្ខឡោនទី៥ប្រើតែក្នុងករណីឃុំសង្កាត់ណាដែលមានជនជាតិដើមភាគតិចរស់នៅ ប្រសិនបើ ឃុំ សង្កាត់ គ្មានជនជាតិដើមភាគតិចរស់នៅទេ មិនចាច់គូសក្ខឡោនទី៥នេះឡើយ ។*

## ជំហានទី៤

## ការកំណត់ទិសដៅនិងយុទ្ធសាស្ត្រវិនិយោគ

៤.១. <u>គោលបំណង</u> :

ដើម្បីសរសេរទិសដៅនិងយុទ្ធសាស្ត្រវិនិយោគ និងសកម្មភាពវិនិយោគសំរាប់រយៈពេល៣ឆ្នាំរបស់ឃុំ សង្កាត់ ។

៤.២. <u>លទ្ធផលរំពឹងទុក</u> : លទ្ធផលរំពឹងទុកសំខាន់ៗនៅក្នុងជំហាននេះ រួមមាន:

- ទិសដៅនិងយុទ្ធសាស្ត្រវិនិយោគឃុំ សង្កាត់ ។
- សកម្មភាពវិនិយោគសំរាប់រយៈពេល៣ឆ្នាំរបស់ឃុំ សង្កាត់ ។

៤.៣. <u>ទីកន្លែង</u> : នៅឃុំ សង្កាត់ ។

៤.៤. <u>រយៈពេល</u> : អាស្រ័យតាមការកំណត់របស់ គ.ផ.ថ ។

៤.៥. <u>សំភារៈត្រូវការ</u> : ក្រដាសផ្ទាំងធំ ហ្វឺត ស្កត់ ផែនទី តារាងជំនួយស្មារតី ។

៤.៦. <u>អ្នកចូលរួមនិងភារកិច្ច</u> :

ដើម្បីអោយការប្រជុំប្រព្រឹត្តទៅប្រកបដោយលទ្ធផលខ្ពស់ ការប្រជុំនេះ ត្រូវមាន មេឃុំ ចៅសង្កាត់ជាប្រធានអង្គប្រជុំ ស្មៀនឃុំសង្កាត់ជាអ្នកកត់ត្រានិងធ្វើកំណត់ហេតុ សមាជិក គ.ផ.ថ ជាអ្នកពិនិត្យផ្តល់យោបល់ និងព្រមព្រៀង អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ ឬគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ ព្រមទាំងអ្នកសំរបសំរួលជាអ្នកសំរបសំរួលការពិភាក្សា ។

៤.៧. <u>ដំណើរការការងារ</u> :

**សកម្មភាព ក) ពិភាក្សាបង្កើតឃ្លាទិសដៅនិងយុទ្ធសាស្ត្រ**

១. ផ្តើមចេញពីតារាងជំនួយស្មារតី៣.២ (កូឡោនទី៤) អ្នកសំរបសំរួលត្រូវជួយ គ.ផ.ថ ដឹកនាំការពិភាក្សា ដោយចាប់ផ្តើមផ្គុំពាក្យនៅក្នុងកូឡោនទី៤នេះ ដើម្បីទទួលបានឃ្លាមួយថ្មីដែលមានទំរង់ជាឃ្លាទិសដៅ និងយុទ្ធសាស្ត្រ ។ ចំពោះគោលបំណងខ្លះ ដែលមានលក្ខណៈជាយុទ្ធសាស្ត្រ ត្រូវកែសំរួលអោយទៅជាឃ្លាយុទ្ធសាស្ត្រពិតប្រាកដ ។

២. បន្ទាប់មកធ្វើការផ្ទៀងផ្ទាត់ឃ្លាទិសដៅទាំងនោះ ដោយធៀបទៅនឹងចក្ខុវិស័យនៃផែនការអភិវឌ្ឍន៍ឃុំសង្កាត់ ដើម្បីកុំអោយការកំណត់ថ្មីនេះ ឃ្លាតឆ្ងាយពីក្របខណ្ឌអភិវឌ្ឍន៍របស់ឃុំសង្កាត់ ដែលបានកំណត់ក្នុងរយៈពេលប្រាំឆ្នាំ ។

**សកម្មភាព ៩) កំណត់សកម្មភាពដែលឆ្លើយតបយុទ្ធសាស្ត្រវិនិយោគ**

១. ផ្អែកតាមតារាងជំនួយស្មារតី៣.២ ធ្វើការសរសេរឡើងវិញនូវដំណោះស្រាយ ដែលបានព្រមព្រៀងឱ្យទៅជាទំរង់សកម្មភាព ដែលនឹងត្រូវសរសេរបំលែងអោយទៅជាឈ្មោះគំរោងនៅជំហានទី៥ ។ អ្នកសំរបសំរួលអាចប្រើតារាងជំនួយស្មារតីទី៤ ដើម្បីជួយ គ.ផ.ថ ។

២. នៅពេលយកផ្នែកនេះទៅបញ្ចូលក្នុងជំពូកទី២ នៃកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់ឃុំសង្កាត់ នោះអាចសរសេរជាទំរង់តារាងជំនួយស្មារតី ឬអធិប្បាយជាអត្ថបទក៏បាន ប៉ុន្តែមិនគួរប្រើទាំងពីររបៀបនេះទេក្នុងឯកសារតែមួយ ព្រោះនាំអោយបង្កើនការងារពីរដង និងច្រំដែល។

## ៤. តារាងជំនួយស្មារតីសំរាប់ប្រើក្នុងជំហានទី៤

*របៀបកត់ត្រាកំណត់ចេញជាឃ្លាសង្ខេបទិសដៅ យុទ្ធសាស្ត្រ ដោយផ្អែកលើពត៌មានក្នុងជំហានទី៣*

| | |
|---|---|
| ទិសដៅ (ផ្នែកសេដ្ឋកិច្ច) | |
| យុទ្ធសាស្ត្រ | សកម្មភាព |
| ១. ........ | ១.១ ........... |
| | ១.២. ........... |
| ២. ....... | ២.១. ............ |
| | ២.២. ............ |
| | ២.៣. ............ |
| | ........... |
| ទិសដៅ (ផ្នែកសង្គមកិច្ច) | |
| យុទ្ធសាស្ត្រ | សកម្មភាព |
| ១. ........ | ១.១ ............ |
| | ១.២. ........... |
| ២. ....... | ២.១. ........... |
| | ២.២. ........... |

## ជំហានទី៥
## ការកំណត់គំរោងដែលត្រូវវិនិយោគ

៥.១. <u>គោលបំណង</u> :

ដើម្បីបំលែងសកម្មភាពអោយទៅជាគំរោងវិនិយោគបីឆ្នាំរំកិល ដែលមានឈ្មោះគំរោង ទីតាំងរបស់គំរោង និង ទំហំគំរោង និងតំលៃគំរោងចាន់ស្មាន ។

៥.២. <u>លទ្ធផលរំពឹងទុក</u> :

- បញ្ជីគំរោង និងតំលៃចាន់ស្មានគំរោង ។

៥.៣. <u>ទីកន្លែង</u> : នៅឃុំ សង្កាត់ ។

៥.៤. <u>រយៈពេល</u> : អាស្រ័យតាមកាលកំណត់របស់ គ.ជ.ថ ។

៥.៥. <u>សំភារៈត្រូវការ</u> : ក្រដាសផ្ទាំងធំ ហ្វឺត ស្កត់ ម៉ាស៊ីនគិតលេខ តារាងជំនួយស្មារតី ។

៥.៦. <u>អ្នកចូលរួមនិងភារកិច្ច</u> :

ការប្រជុំនេះ ត្រូវមាន មេឃុំ ចៅសង្កាត់ជាប្រធានអង្គប្រជុំ ស្មៀនឃុំសង្កាត់ជាអ្នកកត់ត្រានិងធ្វើកំណត់ហេតុ សមាជិក គ.ជ.ថ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ ឬអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ ជាអ្នកផ្តល់យោបល់ពិភាក្សានិងព្រមព្រៀង ព្រមទាំងអ្នកសំរបសំរួល ជាអ្នកសំរបសំរួលការពិភាក្សា និងចាំបាច់ត្រូវមានតំណាងជនជាតិដើមភាគតិចចូលរួមឯកភាព (បើមាន) ។

៥.៧. <u>ដំណើរការការងារ</u> :

១. អ្នកសំរបសំរួល ត្រូវជួយឱ្យ គ.ជ.ថ លើកយកសកម្មភាពទាំងអស់ក្នុងជំហានទី៤ មកបំលែងជាឈ្មោះគំរោង ដាក់បញ្ចូលលក្នុងក្រឡោនទី២នៃតារាងជំនួយស្មារតីទី៥ ។

២. បន្ទាប់មក បំពេញរាល់ពត៌មានត្រូវការក្នុងក្រឡោននិមួយៗ ដែលមានសារៈសំខាន់សំរាប់អោយ គ.ជ.ថ ធ្វើការពិចារណា ។ ចំពោះលេខរៀងគំរោង ត្រូវដាក់លេខរៀងតាមផ្នែក ។ អាទិភាពនៃគំរោង ត្រូវយកតាមអាទិភាពនៃដំណោះស្រាយដែលបានឯកភាពក្នុងជំហានទី៣ ។

៣. ដើម្បីអោយមានភាពស៊ីសង្វាក់ទៅនឹងកម្មវិធីវិនិយោគឆ្នាំចាស់ អ្នកសំរបសំរួលត្រូវជួយអោយ គ.ជ.ថ ធ្វើការពិភាក្សាអំពីគំរោងវិនិយោគដែលធ្លាប់ស្នើឡើងក្នុងសមាហរណកម្មផែនការថ្នាក់ស្រុកខណ្ឌក្នុងពេលកន្លងមក ដើម្បីពិនិត្យពីស្ថានភាពអនុវត្ត ថាគំរោងនោះបានអនុវត្តហើយឬនៅ ?។ បើមិនទាន់បានអនុវត្ត តើមកពីមូលហេតុអ្វីខ្លះ ? តើគំរោងទាំងនោះនៅតែចាំបាច់ ឬត្រូវការផ្លាស់ប្តូរទីតាំង ឬក៏ត្រូវលុបចោលជាស្ថាពរ ? ។ បន្ទាប់មកធ្វើការគូស(✓)ក្នុងក្រឡោនទី៣នៃតារាងជំនួយស្មារតីទី៥ដើម្បីអោយដឹងថា តើគំរោងដែលស្នើឡើងឆ្នាំនេះ ស្របគ្នាប៉ុន្មានជាមួយនឹងគំរោងឆ្នាំមុន ។

៤.

## ៥. តារាងជំនួយស្មារតីសំរាប់ប្រើក្នុងជំហានទី៥

| ល.រ | ឈ្មោះគំរោង | គំរោងឆ្នាំមុន | ប្រភេទ | ទីតាំងគំរោង | ចំនួនលទ្ធផល | តំលៃប៉ាន់ស្មាន | អ្នកទទួលផល | | អាទិភាព | យោបល់ឯកភាពរបស់ជនជាតិដើមភាគតិច* |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | ប្រភេទ | ចំនួន | | |
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 |
| **ផ្នែកសេដ្ឋកិច្ច** | | | | | | | | | | |
| ១ | | | | | | | | | | |
| ២ | | | | | | | | | | |
| **ផ្នែកសង្គមកិច្ច** | | | | | | | | | | |
| ១ | | | | | | | | | | |
| ២ | | | | | | | | | | |
| **ផ្នែកធនធានធម្មជាតិនិងបរិស្ថាន** | | | | | | | | | | |
| ១ | | | | | | | | | | |
| ២ | | | | | | | | | | |
| **ផ្នែកសេវាកម្មរដ្ឋបាលនិងសន្តិសុខ** | | | | | | | | | | |
| ១ | | | | | | | | | | |
| ២ | | | | | | | | | | |
| **ផ្នែកយេនឌ័រ** | | | | | | | | | | |
| ១ | | | | | | | | | | |
| ២ | | | | | | | | | | |

** ក្រឡានទី១១ ត្រូវគូសបន្ថែម តែចំពោះឃុំសង្កាត់ណា ដែលមានជនជាតិដើមភាគតិចរស់នៅ ។*

# ជំហានទី៦

## ការព្យាករណ៍ទុនវិនិយោគ

៦.១. <u>គោលបំណង</u> :

ដើម្បីអោយដឹងថាឃុំសង្កាត់ នៅឆ្នាំក្រោយអាចមាន ថវិកាសំរាប់វិនិយោគប៉ុន្មាន ។

៦.២. <u>លទ្ធផលរំពឹងទុក</u> : ចំនួនថវិកាចាំនស្មានសំរាប់ជាទុនវិនិយោគក្នុងឆ្នាំខាងមុខ ។

៦.៣. <u>ទីកន្លែង</u> : ឃុំសង្កាត់

៦.៤. <u>រយៈពេល</u> : អាស្រ័យតាមការកំណត់របស់ គ.ផ.ថ ។

៦.៥. <u>សំភារៈត្រូវការ</u> : ក្រដាសផ្ទាំងធំ ហ្វឺត ស្កត់ ។

៦.៦. <u>អ្នកចូលរួមនិងភារកិច្ច</u> :

ការប្រជុំនេះ ត្រូវមានមេឃុំ ចៅសង្កាត់ជាប្រធានអង្គប្រជុំ ស្មៀនឃុំសង្កាត់ជាអ្នកកត់ត្រានិងធ្វើកំណត់ហេតុ គណនេយ្យករឃុំសង្កាត់ជាអ្នកផ្តល់ពត៌មាននិងពន្យល់ពីខ្ទង់ថវិកា សមាជិក គ.ផ.ថ អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ ជាអ្នកពិភាក្សានិងព្រមព្រៀង ហើយអ្នកសំរបសំរួលជាអ្នកសំរបសំរួលការពិភាក្សា ។

៦.៧. <u>ដំណើរការការងារ</u> :

១. យោងតាមមាត្រា៤នៃអនុក្រឹត្យលេខ១៦ ស្តីពីមូលនិធិឃុំសង្កាត់ ក្រុមប្រឹក្សាមូលនិធិឃុំសង្កាត់ត្រូវប្រកាសជូនឃុំសង្កាត់នូវធនធានត្រូវទទួលបានប្រចាំឆ្នាំ និងធ្វើការព្យាករណ៍ធនធានដែលឃុំសង្កាត់ ត្រូវទទួលបានសំរាប់រយៈពេល៣ឆ្នាំទៅមុខ យ៉ាងយូរបំផុតត្រឹមថ្ងៃទី០១ ខែតុលា (មាត្រា១១) ។

២. ក្នុងករណីពត៌មានផ្តល់អោយមិនទាន់ អ្នកសំរបសំរួលត្រូវជួយ គ.ផ.ថ ដឹកនាំការពិភាក្សា និងសំរេចរក្សាទុកជំហាននេះនៅពេលក្រោយ ដោយចាត់ទុកជាបណ្តោះអាសន្នថា គំរោងទាំងអស់ដែលបានរៀបចំគ្រោងឡើងនៅជំហានទី៥ ជាគំរោងគ្មានថវិកាអនុវត្ត ដែលត្រូវស្វែងរកទុនពីប្រភពផ្សេងៗមកគាំទ្រ ហើយត្រូវចាប់ផ្តើមការងារជំហានទី៧ភ្លាមតែម្តង ។

៣. ពត៌មានអំពីលទ្ធភាពនៃថវិកា សំរាប់ការអនុវត្តគំរោងនៅឆ្នាំបន្ទាប់ (បើមាន) អាចសង្ខេបតាមទំរង់នៃតារាងជំនួយស្មារតីទី៦ ។

## ៦. គារាងជំនួយស្មារតីសំរាប់ជំហានទី៦

*ការចាត់ស្ថានលទ្ធភាពថវិកាវិនិយោគក្នុងរយៈពេល៣ឆ្នាំ*

| លេខកូដ | ខ្ទង់ថវិកា | ឆ្នាំ២០០៦ | ឆ្នាំ២០០៧ | ឆ្នាំ២០០៨ |
|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 |
| **ចំណូលមូលធន** | | | | |
| ៧៦ | ចំណូលមូលនិធិបំរុង | | | |
| ៧៧ | ចំណូលពីការផ្ទេរមូលនិធិឃុំសង្កាត់សំរាប់អភិវឌ្ឍន៍មូលដ្ឋាន | | | |
| ៧៨ | ចំណូលពីការរួមចំណែករបស់ប្រជាជនទៅក្នុងគំរោង | | | |
| ៧៩ | ចំណូលមូលធនផ្សេងៗ | | | |
| | **សរុបចំណូលមូលធន** | | | |
| **ចំណាយមូលធន** | | | | |
| ៦៧ | ចំណាយវិនិយោគផ្នែករដ្ឋបាល | | | |
| ៦៨ | ចំណាយវិនិយោគអភិវឌ្ឍន៍មូលដ្ឋាន | | | |
| | **សរុបចំណាយមូលធន** | | | |

## ជំហានទី៧

## ការរៀបចំតារាងគំរោងវិនិយោគជាអាទិភាព

៧.១. គោលបំណង :

ជ្រើសរើស និងឯកភាពក្នុង គ.ផ.ថ ទៅលើបញ្ជីគំរោងអាទិភាព សំរាប់ចូលរួមសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុកខណ្ឌ ។

៧.២. លទ្ធផលរំពឹងទុក :

- បញ្ជីគំរោងជាអាទិភាពខ្ពស់របស់ឃុំសង្កាត់ ។
- ការត្រៀមលក្ខណៈរៀបចំចូលរួមសមាហរណកម្ម ។

៧.៣. ទីកន្លែង : ឃុំសង្កាត់ ។

៧.៤. រយៈពេល : អាស្រ័យតាមការកំណត់របស់ គ.ផ.ថ តែបញ្ជីគំរោងជាអាទិភាពខ្ពស់របស់ឃុំសង្កាត់ ត្រូវតែបានផ្ញើដល់មន្ទីរផែនការខេត្តក្រុង តាមកាលកំណត់ពីស្ថាប័នមានសមត្ថកិច្ចនៅថ្នាក់ជាតិ ។

៧.៥. សំភារៈត្រូវការ : ក្រដាស ហ្វឺត ស្កត់ លទ្ធផលជំហានទី៥ និងជំហានទី៦(បើមាន) ។

៧.៦. អ្នកចូលរួមនិងភារកិច្ច :

ការប្រជុំនេះ ត្រូវមានមេឃុំចៅសង្កាត់ជាប្រធានអង្គប្រជុំ ស្មៀនឃុំសង្កាត់ ជាអ្នកកត់ត្រានិងធ្វើកំណត់ហេតុ សមាជិក គ.ផ.ថ សមាជិកគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ ឬអ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ ជាអ្នកពិភាក្សា ហើយអ្នកសំរបសំរួលជាអ្នកជួយដំណើរការពិភាក្សា ។

៧.៧. ដំណើរការការងារ :

**សកម្មភាព ក) រៀបចំតារាងបញ្ជីគំរោងអាទិភាពខ្ពស់ឃុំសង្កាត់**

១. អ្នកសំរបសំរួល ត្រូវជួយមេឃុំ ចៅសង្កាត់ ដឹកនាំ គ.ផ.ថ ពិភាក្សាដោយយោងពត៌មានដែលបានពិភាក្សានៅក្នុងជំហានទី៥ និងជំហាន៦ (បើមាន) ដើម្បីធ្វើការសន្ទនាអំពីលទ្ធភាពក្នុងការអនុវត្តគំរោង និងការសំរេចចុងក្រោយត្រូវស្រង់ឈ្មោះគំរោងបញ្ចូលទៅក្នុងតារាងឯកភាពមួយ (តារាងទី៧)សំរាប់ផ្ញើទៅកាន់មន្ទីរផែនការខេត្តក្រុង (ឱ្យទាន់តាមកាលកំណត់ពីថ្នាក់ជាតិ) ដោយសរសេរតាមលំដាប់លំដោយនូវ :

១. ក្រឡោនទី១ : លេខរៀងគំរោងតាមផ្នែកទាំងប្រាំ ។
២. ក្រឡោនទី២ : ឈ្មោះគំរោង ដែលបានកំណត់នៅក្នុងជំហានទី៥រួចមកហើយ ។
៣. ក្រឡោនទី៣ : ប្រភេទគំរោង ។
៤. ក្រឡោនទី៤ : ទីតាំងគំរោងដែលត្រូវអនុវត្ត ។

៥. កូឡោនទី៥ : ចំនួនលទ្ធផលគំរោង ឬទំហំរបស់គំរោង ។

៦. កូឡោនទី៦ : តំលៃចាន់ស្មានសរុប។

៧. កូឡោនទី៧និងទី៨ : ចំនួនអ្នកទទួលផលសរុប និងស្ត្រី ។

៨. កូឡោនទី៩ : រក្សាទំនេរសិន (សំរាប់តំណាងឃុំសង្កាត់ប្រើប្រាស់ ដើម្បីកត់ត្រាលទ្ធផលក្នុងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុកខណ្ឌ )។

២. គ.ផ.ថ ត្រូវផ្ញើបញ្ជីគំរោងជាអាទិភាពខ្ពស់របស់ឃុំសង្កាត់ខ្លួន (តារាងទី៧) និងតារាងលទ្ធផលដែលបានអនុវត្តគំរោងកន្លងមក ទៅមន្ទីរផែនការខេត្ត ក្រុង ដើម្បីប្រើប្រាស់ក្នុងការរៀបចំតារាងម៉ាទ្រិចរួម ។ ត្រូវចងចាំថា ការផ្ញើជូននេះ ត្រូវធ្វើឡើងអោយបានតាមកាលកំណត់ពីស្ថាបន័មានសមត្ថកិច្ចនៅថ្នាក់ជាតិ ។

៣. អ្នកសំរបសំរួល គួរផ្តល់យោបល់អោយឃុំសង្កាត់មានទំនាក់ទំនងល្អជាមុន ជាមួយអ្នកគាំទ្រគំរោងដូចជា អង្គការ សប្បុរសជន ឬមន្ទីរជំនាញនានា ជាដើម ដើម្បីស្វែងយល់អំពីគោលបំណង ទំនោរនៃការគាំទ្រ និងជ្រើសរើសគំរោងដែលសមស្រប សំរាប់ដាក់បញ្ចូលទៅក្នុងបញ្ជីគំរោង អាទិភាពផ្ញើទៅមន្ទីរផែនការ ។ ម្យ៉ាងទៀត អ្នកសំរបសំរួល គួររំលឹកថាឃុំសង្កាត់ត្រូវផ្អែកលើ បទពិសោធន៍ដែលទទួលបានពីសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុកខណ្ឌនាបណ្តាឆ្នាំមុនៗ ដើម្បីធ្វើការចាន់ស្មានពីប្រភេទគំរោងដែលភាគច្រើនមានការគាំទ្រនៅក្នុងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌ ។

**តារាងទី៧ :** គំរោងវិនិយោគជា "អាទិភាពខ្ពស់" របស់ឃុំសង្កាត់ដែលត្រូវបញ្ជូនទៅមន្ទីរផែនការខេត្តក្រុង ដើម្បីស្នើសុំ បញ្ចូលក្នុងរបៀបវារៈពិភាក្សាក្នុងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុកខណ្ឌ សំរាប់ឆ្នាំ.......របស់ឃុំសង្កាត់.........

| ល.រ | ឈ្មោះគំរោង | ប្រភេទ | ទីតាំង | ចំនួនលទ្ធផល | តំលៃចាំន់ស្មាន | អ្នកទទួលផល | | កំណត់សំគាល់ ក្នុងសិក្ខាសាលា សមាហរណកម្មផែនការស្រុកខណ្ឌ |
|---|---|---|---|---|---|---|---|---|
| | | | | | | សរុប | ស្រី | |
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 |
| **ផ្នែកសេដ្ឋកិច្ច** | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| **ផ្នែកសង្គមកិច្ច** | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| **ផ្នែកធនធានធម្មជាតិនិងបរិស្ថាន** | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| **ផ្នែកសេវាកម្មរដ្ឋបាលនិងសន្តិសុខ** | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| **ផ្នែកយេនឌ័រ** | | | | | | | | |
| | | | | | | | | |
| | | | | | | | | |

*សំគាល់ : ពេលស្រង់តារាងទី៧នេះផ្ញើទៅមន្ទីរផែនការ មិនចាំបាច់គូសកូឡោនទី៩ទេ*

**តារាងលទ្ធផលដែលបានអនុវត្តគំរោងក្នុងឆ្នាំ........ ឃុំ ............**

| ល.រ | ឈ្មោះគំរោង | ផ្នែក | ទីតាំងអនុវត្ត | ឯកតា | ទំហំ | តំលៃ | អ្នកទទួលខុសត្រូវ ឬអ្នកឧបត្ថម្ភ |
|---|---|---|---|---|---|---|---|
| ក. គំរោងឬសកម្មភាពដែលបានចុះកិច្ចព្រមព្រាងបណ្តោះអាសន្ន បានអនុវត្តរួចជាស្ថាពរ | | | | | | | |
| | | | | | | | |
| | | | | | | | |
| ខ. គំរោងឬសកម្មភាពបានចុះកិច្ចព្រមព្រាងបណ្តោះអាសន្នដែលកំពង់អនុវត្ត | | | | | | | |
| | | | | | | | |
| | | | | | | | |
| គ. គំរោងឬសកម្មភាពបានចុះកិច្ចព្រមព្រាងបណ្តោះអាសន្ន ដែលមិនបានអនុវត្ត | | | | | | | |
| | | | | | | | |
| | | | | | | | |
| ឃ. គំរោងឬសកម្មភាពដែលបានគាំទ្រក្រោយសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុកខណ្ឌ | | | | | | | |
| | | | | | | | |
| | | | | | | | |
| ង. គំរោងឬសកម្មភាពដែលប្រើប្រាស់មូលនិធិឃុំ | | | | | | | |
| | | | | | | | |
| | | | | | | | |

**សកម្មភាព ៦) ការត្រៀមរៀបចំសិក្ខាសាលាសមាហរណកម្ម**

១. បន្ទាប់ពីកំណត់គំរោងក្នុងតារាងទី៧និងតារាងលទ្ធផលដែលបានអនុវត្តរួចហើយ អ្នកសំរបសំរួលត្រូវពិភាក្សាជាមួយ គ.ផ.ថ ដើម្បីចាត់តាំងអ្នកដែលត្រូវចូលរួម ក្នុងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌ ។ តាមធម្មតាមេឃុំ ចៅសង្កាត់ ជាអ្នកទទួលខុសត្រូវទាំងស្រុងក្នុងការយកគំរោងដែលបានឯកភាពទៅបង្ហាញនៅក្នុងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌ ។ ប៉ុន្តែមេឃុំ ចៅសង្កាត់អាចផ្តល់ឱកាសដល់អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំសង្កាត់ ឬអ្នកដែលខ្លួនគិតថាមានសមត្ថភាពឡើងបង្ហាញពីគំរោងជំនួសខ្លួន នៅក្នុងសិក្ខាសាលាសមាហរណកម្មបានដែរ ។

២. អ្នកសំរបសំរួល អាចជួយផ្តល់ការបង្ហាត់បង្ហាញដល់អ្នកដែលត្រូវឡើងបង្ហាញ នូវវិធីសាស្ត្រនានាសំរាប់ប្រើនៅពេលចរចារ ។ ការបង្ហាត់បង្ហាញនេះ អាស្រ័យទៅតាមលទ្ធភាពអ្នកសំរបសំរួលម្នាក់ៗ ហើយមិនតំរូវអោយអនុវត្តន៍ចំពោះគ្រប់ឃុំសង្កាត់នោះទេ ។

៣. សំភារៈដែល គ.ផ.ថ ត្រូវរៀបចំសំរាប់ចូលរួមសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុកខណ្ឌ រួមមាន : តារាងបញ្ជីគំរោងស្នើ ផែនទីឃុំសង្កាត់ តារាងលទ្ធផលដែលបានអនុវត្តគំរោងក្នុងឆ្នាំកន្លងមក នៅក្នុងក្រដាសផ្ទាំងធំទាំងអស់ ។ ការរៀបចំនេះគឺធ្វើយ៉ាងណា ដើម្បីទាក់ទាញអោយមានការចាប់អារម្មណ៍ ជាពិសេសទៅលើគំរោងស្នើរបស់ឃុំសង្កាត់ ។ ប្រការសំខាន់នោះគឺអ្នកដែលតំណាងឃុំ សង្កាត់ ឡើងធ្វើការបង្ហាញពីលទ្ធផលដែលបានអនុវត្តគំរោងក្នុងឆ្នាំកន្លងមក និងគំរោងថ្មីស្នើសុំការគាំទ្រ ត្រូវតែបានជ្រើសរើសដោយប្រុងប្រយ័ត្ន ដោយផ្អែកទៅលើភាពប៉ិនប្រសព្វក្នុងការនិយាយបង្ហាញបានច្បាស់លាស់ ហើយមានជំនាញក្នុងការចរចារ ។

# ជំហានទី៨

## ការរៀបចំសមាហរណកម្មផែនការថ្នាក់ស្រុកខណ្ឌ

៨.១. <u>គោលបំណង</u> :

ផ្តល់ឱកាសអោយមានការផ្សារភ្ជាប់ រវាងដំណើរការកសាងផែនការមូលដ្ឋានជាមួយនឹងផែនការរបស់មន្ទីរជំនាញ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល និងភាគីអ្នកផ្តល់ជំនួយនានា និងដើម្បីជួយតំរង់ទិសសកម្មភាពរបស់មូលដ្ឋាន អោយស្របតាមគោលនយោបាយអភិវឌ្ឍន៍ជាតិ ឬវិស័យនានា ។

៨.២. <u>លទ្ធផលរំពឹងទុក</u> :

កិច្ចព្រមព្រៀងបណ្តោះអាសន្នរវាងក្រុមប្រឹក្សាឃុំសង្កាត់ ជាមួយដៃគូផ្សេងៗ ។

៨.៣. <u>ទីកន្លែង</u> : ស្រុក ខណ្ឌ ។

៨.៤. <u>រយៈពេល</u> : ១-២ថ្ងៃ អាស្រ័យទៅតាមស្ថានភាពជាក់ស្តែង ។

៨.៥. <u>សំភារៈត្រូវការ</u> : ក្រដាសផ្ទាំងធំ ហ្វឺត ស្កត់ តារាងម៉ាទ្រិច ។

៨.៦. <u>អ្នកចូលរួមនិងភារកិច្ច</u> :

សិក្ខាសាលានេះ ត្រូវមាន អភិបាលស្រុកខណ្ឌជាអធិបតី មន្ទីរផែនការជាអ្នកសំរបសំរួល តំណាងឃុំសង្កាត់ជាអ្នកស្នើគំរោង និងមន្ទីរជំនាញ អង្គការ សប្បុរសជន ជាអ្នកគាំទ្រគំរោង ។

៨.៧. <u>ដំណើរការការងារ</u> :

ការរៀបចំសកម្មភាពការងារ នឹងត្រូវរៀបចំណែនាំដោយឡែកដោយក្រសួងផែនការ ។

# ជំហានទី៩
## ការសំរេចចុងក្រោយលើគំរោងនានាក្នុងកម្មវិធីវិនិយោគឃុំសង្កាត់

៩.១. <u>គោលបំណង</u> :

ត្រូវពិនិត្យជ្រើសរើសគំរោងដែលត្រូវប្រើធនធានថវិកាឃុំសង្កាត់ តាមលក្ខណៈវិនិច្ឆ័យដែលសមស្របបំផុត ។

៩.២. <u>លទ្ធផលរំពឹងទុក</u> :

- តារាងគំរោងវិនិយោគមានការគាំទ្រ (តារាង ៣.ក)
- តារាងថវិកាវិនិយោគតាមប្រភពផ្តល់ (តារាង ៣.ខ)

៩.៣. <u>ទីកន្លែង</u> : នៅឃុំ សង្កាត់

៩.៤. <u>រយៈពេល</u> : តាមការកំណត់របស់ គ.ផ.ថ ។

៩.៥. <u>សំភារៈត្រូវការ</u> : ក្រដាស ហ្វីត ស្កត់ តារាងគំរោងវិនិយោគ ។

៩.៦. <u>អ្នកចូលរួមនិងភារកិច្ច</u> :

ក្នុងជំហាននេះ ត្រូវមានមេឃុំចៅសង្កាត់ជាប្រធាន ស្មៀនឃុំសង្កាត់ជាអ្នកកត់ត្រា និងធ្វើកំណត់ហេតុ សមាជិក គ.ផ.ថ ជនបង្គោលទទួលបន្ទុកកិច្ចការនារីនិងកុមារ ចូលរួមផ្តល់យោបល់និងឯកភាព អ្នកសំរបសំរួលជាអ្នកជួយបំផុសការពិភាក្សា ។

៩.៧. <u>ដំណើរការការងារ</u> :

**សកម្មភាព ក) សំរេចវិភាជន៍ថវិកាគំរោងស្របតាមលទ្ធផលសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក**

១. បន្ទាប់ពីសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក អ្នកសំរបសំរួលត្រូវជួយ គ.ផ.ថ ធ្វើការកែតំរូវតារាងទី៧ ផ្អែកលើកិច្ចព្រមព្រៀងបណ្តោះអាសន្ន និងតារាងប៉ាន់ស្មានលទ្ធភាពធនធានឃុំសង្កាត់ (តារាងទី៦) ។

២. ការកែតំរូវទាំងនោះអាចមានដូចជា : បន្ថែមគំរោងថ្មី កែសំរួលឈ្មោះគំរោង ទីតាំងគំរោង ទំហំគំរោង តំលៃគំរោង។ល។ ដើម្បីបញ្ចូលទៅក្នុងតារាង ៣.ក ។

៣. ដើម្បីធ្វើការបែងចែកថវិកាអោយបានត្រឹមត្រូវ អ្នកសំរបសំរួលត្រូវជួយគូសសំគាល់គំរោងដែលទទួលបានការគាំទ្រ រួចទើបយកគំរោងនៅសល់មកធ្វើការជ្រើសរើស ប្រៀបធៀបទៅតាមលទ្ធភាពថវិការបស់ឃុំសង្កាត់ ដោយពិភាក្សាព្រមព្រៀងថាតើគំរោងណាខ្លះ ដែលត្រូវប្រើថវិកាឃុំសង្កាត់នោះ ។ ចំពោះគំរោងដែលគ្មានការគាំទ្រ ឬគ្មានលទ្ធភាពអនុវត្តទាល់តែសោះ គួររក្សាទុកសំរាប់ឆ្នាំក្រោយទៀត ។

៤. តារាង៣.ក ជាតារាងគំរោងវិនិយោគដែលទទួលបានការគាំទ្រ និងគំរោងដែលប្រើប្រាស់ថវិកាឃុំសង្កាត់ដើម្បីអនុវត្ត ។ ហេតុនេះ តារាង៣.ក មិនអាចបញ្ចប់បាន ប្រសិនបើ គ.ផ.ថ

មិនដឹងច្បាស់ពីថវិកាឃុំសង្កាត់របស់ខ្លួន ដូចបានពិភាក្សាក្នុងជំហានទី៦ និងមិនអាចបំពេញព័ត៌មានបន្ថែម ដូចជាអ្នកធ្វើការសិក្សាគំរោង (ក្ខឡោនទី១០) ប្រភពគាំទ្រដែលអាចស្នើសុំ (ក្ខឡោនទី១១) អ្នកទទួលបន្ទុក (ក្ខឡោនទី១២) ។ ធ្វើបែបនេះ ដើម្បីងាយស្រួលសំគាល់ថាតើការគាំទ្រមានតំលៃចាន់ស្មានប៉ុន្មាន ក្នុងឆ្នាំណាខ្លះ ។

៥. តារាងគំរោងថ្មីនេះ គួរចំលងជូនទៅក្រុមគាំទ្របច្ចេកទេស ដើម្បីរៀបចំផែនការការងារជួយគាំទ្រដល់ការសិក្សាគំរោងប្រសិនបើចាំបាច់ ។

## តារាង ៣.ក) តារាងគំរោងវិនិយោគឃុំសង្កាត់បីឆ្នាំរំកិល

| ល.រ | ឈ្មោះគំរោង | ទីតាំង | ចំនួនលទ្ធផល | | | តំលៃប៉ាន់ស្មាន | អ្នកទទួលផល | | អ្នកធ្វើការសិក្សាគំរោង | ប្រភពគាំទ្រដែលអាចស្នើសុំបាន | អ្នកទទួលបន្ទុក |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០០៦ | ២០០៧ | ២០០៨ | | សរុប | ស្រី | | | |
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
| **គំរោងកំពុងដំណើរការ(បើមាន)** | | | | | | | | | | | |
| 1 | | | | | | | | | | | |
| 2 | | | | | | | | | | | |
| 3 | | | | | | | | | | | |
| **គំរោងវិនិយោគដែលមានការគាំទ្រ** | | | | | | | | | | | |
| **ក. ផ្នែកសេដ្ឋកិច្ច** | | | | | | | | | | | |
| 1 | | | | | | | | | | | |
| 2 | | | | | | | | | | | |
| សរុបតំលៃប៉ាន់ស្មានផ្នែកសេដ្ឋកិច្ច | | | | | | | | | | | |
| **ខ. ផ្នែកសង្គមកិច្ច** | | | | | | | | | | | |
| 1 | | | | | | | | | | | |
| 2 | | | | | | | | | | | |
| សរុបតំលៃប៉ាន់ស្មានផ្នែកសង្គមកិច្ច | | | | | | | | | | | |
| **គ. ផ្នែកធនធានធម្មជាតិនិងបរិស្ថាន** | | | | | | | | | | | |
| 1 | | | | | | | | | | | |
| 2 | | | | | | | | | | | |
| សរុបតំលៃប៉ាន់ស្មានផ្នែកធនធានធម្មជាតិនិងបរិស្ថាន | | | | | | | | | | | |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| **ឃ. ផ្នែកសេវាកម្មរដ្ឋបាលនិងសន្តិសុខ** | | | | | | | | | | | |
| 1 | | | | | | | | | | | |
| 2 | | | | | | | | | | | |
| សរុបតំលៃប៉ាន់ស្មានផ្នែកសេវាកម្មរដ្ឋបាលនិងសន្តិសុខ | | | | | | | | | | | |
| **ង. ផ្នែកយេនឌ័រ** | | | | | | | | | | | |
| 1 | | | | | | | | | | | |
| 2 | | | | | | | | | | | |
| សរុបតំលៃប៉ាន់ស្មានផ្នែកយេនឌ័រ | | | | | | | | | | | |
| សរុបរួមតំលៃប៉ាន់ស្មានគំរោងមានការគាំទ្រ | | | | | | | | | | | |
| **គំរោងវិនិយោគដែលគ្មានការគាំទ្រ** | | | | | | | | | | | |
| **ក. ផ្នែកសេដ្ឋកិច្ច** | | | | | | | | | | | |
| 1 | | | | | | | | | | | |
| 2 | | | | | | | | | | | |
| សរុបតំលៃប៉ាន់ស្មានផ្នែកសេដ្ឋកិច្ច | | | | | | | | | | | |
| **ខ. ផ្នែកសង្គមកិច្ច** | | | | | | | | | | | |
| 1 | | | | | | | | | | | |
| 2 | | | | | | | | | | | |
| សរុបតំលៃប៉ាន់ស្មានផ្នែកសង្គមកិច្ច | | | | | | | | | | | |
| **គ. ផ្នែកធនធានធម្មជាតិនិងបរិស្ថាន** | | | | | | | | | | | |
| 1 | | | | | | | | | | | |
| 2 | | | | | | | | | | | |
| សរុបតំលៃប៉ាន់ស្មានផ្នែកធនធានធម្មជាតិនិងបរិស្ថាន | | | | | | | | | | | |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| **ឃ. ផ្នែកសេវាកម្មរដ្ឋបាលនិងសន្តិសុខ** | | | | | | | | | | | |
| 1 | | | | | | | | | | | |
| 2 | | | | | | | | | | | |
| សរុបតំលៃចាំន់ស្មានផ្នែកសេវាកម្មរដ្ឋបាលនិងសន្តិសុខ | | | | | | | | | | | |
| **ង. ផ្នែកយេនឌ័រ** | | | | | | | | | | | |
| 1 | | | | | | | | | | | |
| 2 | | | | | | | | | | | |
| សរុបតំលៃចាំន់ស្មានផ្នែកយេនឌ័រ | | | | | | | | | | | |
| សរុបតំលៃចាំន់ស្មានគំរោងគ្មានការគាំទ្រ | | | | | | | | | | | |

៦. អ្នកសំរបសំរួលត្រូវជួយណែនាំ គ.ជ.ថ ក្នុងការបំពេញតារាង៣.ខ ដែលសរុបថវិកាទៅតាមប្រភពផ្តល់ ។

៧. តារាងនេះ នឹងបង្ហាញពីចំណែកនៃការចូលរួមថវិកាវិនិយោគពីប្រភពផ្សេងៗ នៅក្នុងឃុំសង្កាត់ ក្នុងឆ្នាំថវិកា ។ តារាងនេះ ខុសប្លែកពីផែនការថវិកាប្រចាំឆ្នាំរបស់ឃុំសង្កាត់ ដោយសារតែប្រភពថវិកាពីភ្នាក់ងារខាងក្រៅ ។

៨. ការគណនាភាគរយ (កូឡោនទី៤) គឺក្នុងគោលបំណងបង្ហាញថា តើធនធានផ្ទាល់របស់ឃុំ សង្កាត់ (ប្រភពក្នុងឃុំសង្កាត់) មូលនិធិឃុំសង្កាត់ (ប្រភពពីថវិកាជាតិ) និងទុនពីភ្នាក់ងារ (ថវិកាផ្សេងៗ) មានចំណែកយ៉ាងដូចម្តេចដែរ? ។

**តារាង ៣.ខ) តារាងថវិកាវិនិយោគតាមប្រភពផ្តល់**

| ល.រ | ប្រភពថវិកា | ឆ្នាំ២០០៦ | ភាគរយ |
|---|---|---|---|
| 1 | 2 | 3 | 4 |
| ១ | ធនធានផ្ទាល់ខ្លួន (រួមទាំងការចូលរួមរបស់ប្រជាជន) | | |
| ២ | មូលនិធិឃុំសង្កាត់ | | |
| ៣ | សរុបរងទុនភ្នាក់ងារនានាពីក្រៅ | | |
| | **សរុបរួម** | | 100% |
| ៣.១ | មន្ទីរ.............. | | |
| ៣.២ | មន្ទីរ.............. | | |
| ៣.៣ | អង្គការ .......... | | |
| ៣.៤<br>៣.៥ | ភ្នាក់ងារ ..........<br>សប្បុរសជន......... | | |

**សកម្មភាព ខ) ការបែងចែកសមាជិកទទួលខុសត្រូវ**

១. អ្នកសំរបសំរួល ត្រូវជួយ គ.ជ.ថ ក្នុងការពិនិត្យបញ្ជីគំរោងដែលបានសំរេចរួច ដើម្បីបែងចែកអោយសមាជិកក្រុមប្រឹក្សាឃុំទទួលខុសត្រូវតាមដានការអនុវត្ត ។ អ្នកទទួលខុសត្រូវគំរោងនិមួយៗ ត្រូវផ្តល់ពត៌មានលំអិតដល់មេឃុំចៅសង្កាត់ ស្តីពីការអនុវត្តគំរោង ដើម្បីមេឃុំចៅសង្កាត់ អាចធ្វើរបាយការណ៍ឃុំសង្កាត់បាន ។ ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវផ្តល់ឱកាស ដល់អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ ដែលមិនមែនជាសមាជិកនៃក្រុមប្រឹក្សាឃុំសង្កាត់ ក្នុងការទទួលខុសត្រូវតាមដានការអនុវត្តគំរោង ក្នុងគំរោងណាដែលផ្តល់ផលប្រយោជន៍ដល់នារី និងកុមារ ។

២. ការបែងចែកនេះ គឺធ្វើឡើងជាក់ស្តែងទៅតាមគំរោង ដែលមានការគាំទ្រប្រចាំឆ្នាំប៉ុណ្ណោះ ហើយបូកបន្ថែមជារៀងរាល់ឆ្នាំ នៅពេលណាដែលគំរោងត្រូវបានអនុម័តជារៀងរាល់ឆ្នាំ ។

៣. ការបែងចែកបែបនេះ គឺធ្វើអោយសមាជិកក្រុមប្រឹក្សាឃុំ មានភារកិច្ចតាមដានកិច្ចអភិវឌ្ឍន៍ជារៀងរាល់ឆ្នាំ ហើយអាចជួយប្រធានក្រុមប្រឹក្សាឃុំរៀបចំបូកសរុបស្ថានភាពរីកចំរើននៅពេលពាក់កណ្តាល ឬចុងបញ្ចប់នៃអាណត្តិការងាររបស់ខ្លួន ។

# ជំហានទី១០

## ការចងក្រងសៀវភៅកម្មវិធីវិនិយោគឃុំសង្កាត់

១០.១. <u>គោលបំណង</u> :

ប្រមូលផ្តុំឯកសារដែលបានពិភាក្សាគ្រប់ជំហានដូចជា : ការវិភាគស្ថានភាពឃុំសង្កាត់ ទិសដៅ និងយុទ្ធសាស្ត្រ បញ្ជីគំរោងវិនិយោគដែលមានការគាំទ្រ និងគំរោងវិនិយោគដែលគ្មានការគាំទ្រ មកចងក្រងជាសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំ សង្កាត់ ។

១០.២. <u>លទ្ធផលរំពឹងទុក</u> :

សេចក្តីព្រាងកម្មវិធីនិយោគបីឆ្នាំរំកិលរបស់ឃុំសង្កាត់ ។

១០.៣. <u>ទីកន្លែង</u> : នៅឃុំ សង្កាត់

១០.៤. <u>រយៈពេល</u> : មួយសប្តាហ៍ ឬក្នុងរយៈពេលមួយដែលសមស្រប ។

១០.៥. <u>សំភារៈត្រូវការ</u> : ក្រដាស ផែនទី លទ្ធផលពិភាក្សា និងតារាងទាំងអស់ ។

១០.៦. <u>អ្នកចូលរួមនិងភារកិច្ច</u> :

ក្រុមការងាររបស់ គ.ផ.ថ ជាអ្នកប្រមូលឯកសារនិងចងក្រង អ្នកសំរបសំរួលជាអ្នកផ្តល់អនុសាសន៍។

១០.៧. <u>ដំណើរការការងារ</u> :

១. អ្នកសំរបសំរួលត្រូវជួយផ្តល់អនុសាសន៍ដល់ គ.ផ.ថ ក្នុងការរៀបចំរាល់ពត៌មានទាំងអស់ពីគ្រប់ជំហានការងារ ដើម្បីរៀបចំអោយទៅជាឯកសារកម្មវិធីវិនិយោគឃុំសង្កាត់តាមទំរង់ ដូចមានពន្យល់លំអិតនៅផ្នែកខាងដើម។

២. ពត៌មានបានមកពីការវិភាគនៅជំហានទី១ ទី២ និងទី៣ ត្រូវប្រើសំរាប់សរសេរជំពូកទី១ ។

៣. ពត៌មាននិងលទ្ធផលក្នុងជំហានទី៤ ត្រូវប្រើដើម្បីសរសេរជំពូកទី២ ។

៤. ចំណែកលទ្ធផលការងារជំហានទី៩ ត្រូវយកមកប្រើសំរាប់បង្កើតជំពូកទី៣ ។

៥. នៅផ្នែកឧបសម្ព័ន្ធនៃសៀវភៅកម្មវិធីវិនិយោគនេះ គ.ផ.ថ ត្រូវធ្វើការពិចារណាបញ្ចូលនូវលទ្ធផលមួយចំនួនដែលបានអនុវត្តកន្លងមក ដូចជាតារាងលទ្ធផលដែលបានអនុវត្តក្នុងឆ្នាំកន្លងមក តារាងវិភាគនិងវាយតំលៃលើដំណោះស្រាយសំរាប់ស្ត្រីនិងកុមារថ្នាក់ ។ ល ។

## ជំហានទី១១

## ការរៀបចំអនុម័តឯកសារកម្មវិធីវិនិយោគឃុំសង្កាត់

១១.១. <u>គោលបំណង</u> :

ដើម្បីពិភាក្សា និងធ្វើការអនុម័តសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំសង្កាត់ ដែលបានកែសំរួល ។

១១.២. <u>លទ្ធផលរំពឹងទុក</u> :

សៀវភៅកម្មវិធីវិនិយោគ៣ឆ្នាំរបស់ឃុំ សង្កាត់ ទទួលបានការអនុម័ត ។

១១.៣. <u>ទីកន្លែង</u> :

ក). នៅខេត្ត ក្រុង

ខ). នៅភូមិ

គ). នៅឃុំ សង្កាត់

១១.៤. <u>រយៈពេល</u> : ក្នុងអំឡុង៤៥ថ្ងៃយ៉ាងច្រើន ។

១១.៥. <u>សំភារៈត្រូវការ</u> : សេចក្តីព្រាងកម្មវិធីវិនិយោគឃុំសង្កាត់ ។

១១.៦. <u>អ្នកចូលរួមនិងភារកិច្ច</u> :

- នៅខេត្តក្រុង អភិបាលខេត្តក្រុង បង្កើតគណៈកម្មការពិនិត្យ ផ្តល់យោបល់ ។
- នៅភូមិ អ្នកភូមិស្តាប់ការពន្យល់របស់ក្រុមប្រឹក្សាឃុំសង្កាត់ និងចោទសួរឬផ្តល់យោបល់បន្ថែមបើមាន ។
- នៅឃុំសង្កាត់ មេឃុំចៅសង្កាត់ជាប្រធានអង្គប្រជុំ ស្មៀនឃុំសង្កាត់ ជាអ្នកកត់ត្រាធ្វើកំណត់ហេតុ សមាជិកក្រុមប្រឹក្សាពិនិត្យផ្តល់យោបល់និងសំរេចអនុម័ត ។

១១.៧. <u>ដំណើរការការងារ</u> :

**សកម្មភាព ក) ផ្ញើសេចក្តីព្រាង ក.វិ.ឃស ទៅអភិបាលខេត្តក្រុង**

នេះគឺជាជំហានមួយដែលអ្នកភូមិ សង្គមស៊ីវិល ក្រុមសមាគម សហគមន៍ និងអ្នកពាក់ពន្ធ័ មានឱកាសផ្តល់មតិយោបល់ និងទស្សនៈ មុនពេលក្រុមប្រឹក្សាឃុំអនុម័តលើ ក.វិ.ឃស ហើយក៏ជាជំហានដែលត្រូវការចាំបាច់នូវដំណើរការមួយ ដែលត្រូវធ្វើឡើងដោយមានការចូលរួម ។

១. សេចក្តីព្រាងកម្មវិធីវិនិយោគឃុំ សង្កាត់នឹងត្រូវធ្វើជូនអភិបាលខេត្តក្រុង តាមរយៈអង្គភាពរដ្ឋបាលមូលដ្ឋានខេត្តក្រុង ដើម្បីពិនិត្យនិងជួយផ្តល់អនុសាសន៍ ។ ការងារនេះធ្វើឡើងដើម្បីធានាថាកម្មវិធីវិនិយោគឃុំសង្កាត់ បានដំណើរការរៀបចំនិងបានចងក្រងស្របទៅនឹងច្បាប់បទបញ្ញត្តិនានា និងសេចក្តីណែនាំជាធរមានទាំងឡាយ ។

២. អភិបាលខេត្ត ក្រុង អាចអោយមន្ទីរពាក់ព័ន្ធជួយផ្តល់មតិយោបល់លើសេចក្តីព្រាងកម្មវិធីវិនិយោគឃុំសង្កាត់ ។ ការពិនិត្យនិងផ្តល់អនុសាសន៍នេះ មិនត្រូវយូរជាងរយៈពេល៤៥ថ្ងៃឡើយ រាប់ពីថ្ងៃដែលខេត្តក្រុង បានទទួលសេចក្តីព្រាងកម្មវិធីវិនិយោគឃុំ សង្កាត់ ។

៣. ការផ្តល់អនុសាសន៍ នឹងត្រូវផ្តល់អោយឃុំវិញជាទំរង់ "ដីកា" ហើយដែលក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវយកមកពិភាក្សាកែសំរួល ឬបន្ថែមចំនុចនានាទៅតាមអនុសាសន៍របស់ថ្នាក់ខេត្ត ដោយមានអ្នកសំរបសំរួលជាអ្នកជួយការងារ ។

**សកម្មភាព ខ) បង្ហាញសេចក្តីព្រាងចំពោះអ្នកភូមិទាំងអស់**

១. ដើម្បីអោយសាធារណៈជនក្នុងឃុំសង្កាត់ អាចមានយោបល់ទៅលើ ក.វិ.ឃស គ.ផ.ថ ត្រូវរៀបចំការបង្ហាញសេចក្តីព្រាងនេះនៅគ្រប់ភូមិ ។ ការបង្ហាញនេះ ត្រូវធ្វើឡើងដោយតំណាងភូមិជាសមាជិករបស់ គ.ផ.ថ ។ ការប្រជុំភូមិ អាចនឹងរៀបចំម្តងមួយភូមិ ឬក៏ធ្វើឡើងច្រើនភូមិរួមគ្នាក្នុងពេលតែមួយ អាស្រ័យទៅលើទីតាំងស្ថានភាពរបស់ភូមិ ចំនួនប្រជាជនក្នុងភូមិ និងពេលវេលា ។ សមាជិកក្រុមប្រឹក្សាឃុំសង្កាត់ ត្រូវបែងចែកពេលវេលារបស់ខ្លួនចូលរួមអោយបានពេញលេញនៅក្នុងការប្រជុំនោះ ។ រយៈពេលប្រជុំមិនគួរប្រើពេលវែងពេកទេ ពេលវេលាសមល្មម គឺមួយព្រឹកឬវែងបំផុតរយៈពេលមួយថ្ងៃ ។ នៅក្នុងកិច្ចប្រជុំនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវលើកទឹកចិត្តនិងជំរុញឱ្យស្ត្រីចូលរួមប្រកបដោយអត្ថន័យ ហើយក្រុមប្រឹក្សាឃុំសង្កាត់ ត្រូវកត់ត្រាចំនួនស្ត្រីចូលរួម ចំនួនលើកដែលស្ត្រីបានបញ្ចេញយោបល់ឬសំណួរ ។ ក្នុងករណីឃុំមានជនជាតិដើមភាគតិចរស់នៅ ចាំបាច់ត្រូវមានជនជាតិដើមភាគតិចចូលរួមឯកភាព ដោយមានការបកប្រែភាសាជូនជនជាតិដើមភាគតិចទាំងនោះ ដើម្បីអាចយល់បាន ។

២. ខ្លឹមសារនៃសេចក្តីព្រាងកម្មវិធីវិនិយោគឃុំ សង្កាត់ ដែលយកទៅបង្ហាញក្នុងការប្រជុំថ្នាក់ភូមិ ត្រូវសង្ខេបអោយបានខ្លី ច្បាស់លាស់ អាចក្តោបខ្លឹមសារទាំងមូលបានអស់ ។ ធ្វើយ៉ាងនេះ គឺអាចទុកពេលអោយសមាជិកនៃអង្គប្រជុំ ធ្វើការបញ្ចេញមតិយោបល់បានច្រើនលើឯកសារព្រាង ។ នៅក្នុងពេលបង្ហាញ ចាំបាច់ត្រូវចាត់តាំងអ្នកកត់ត្រានូវរាល់មតិយោបល់ផ្សេងៗលើកឡើងដោយប្រជាជនក្នុងពេលប្រជុំ ដើម្បីបូកសរុបជូនក្រុមប្រឹក្សាឃុំ នៅពេលប្រជុំអនុម័ត ។

**សកម្មភាព គ) ពិនិត្យនិងសរុបរាល់មតិយោបល់ទាំងអស់**

១. ឯកសារសេចក្តីព្រាងកម្មវិធីវិនិយោគឃុំ សង្កាត់ដែលរៀបចំរួចរាល់ ត្រូវចំលងជូនគ្រប់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីពិនិត្យជាមុន ។

២. អ្នកសំរបសំរួលត្រូវជួយ គ.ផ.ថ ធ្វើការបង្ហាញពីខ្លឹមសារសង្ខេបរួម និងអារម្ភកថាសំរាប់ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ចុះហត្ថលេខា នៅពេលមានការព្រមព្រៀងអនុម័ត ។ ការបង្ហាញនេះ ត្រូវ

សង្ខេបផងដែរអំពីអនុសាសន៍ផ្សេងៗ ដែលទទួលបានពីថ្នាក់ខេត្តក្រុង និងការប្រជុំភូមិ ។ សំណើកែតំរូវឯកសារ ក.វិ.ឃស ទៅតាមអនុសាសន៍ ក៏ត្រូវលើកឡើងសំរាប់ពិភាក្សាផងដែរ ។

**សកម្មភាព ឃ) ក្រុមប្រឹក្សាឃុំពិនិត្យអនុម័ត ក.វិ.ឃស**

១. ការប្រជុំក្រុមប្រឹក្សាឃុំសង្កាត់ធ្វើឡើងនៅឃុំសង្កាត់ ហើយមានចំនួនចូលរួមលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ទាំងមូល ។ សមាជិក គ.ផ.ថ ទាំងអស់អាចចូលរួម ដើម្បីជួយបំភ្លឺចំនុចមិនច្បាស់លាស់មួយចំនួន (បើមាន) ព្រមទាំងរាយការណ៍ពីមតិយោបល់សាធារណៈ និងអនុសាសន៍ជាផ្លូវការពីថ្នាក់ខេត្ត ក្រុង (*មាត្រា២២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់*) ។

២. គ.ផ.ថ ត្រូវរៀបចំឯកសារសេចក្តីព្រាងកម្មវិធីវិនិយោគឃុំសង្កាត់ ជូនគ្រប់សមាជិកក្រុមប្រឹក្សា ដើម្បីធ្វើការពិនិត្យពិចារណាមុនបើកការប្រជុំពិភាក្សា និងអនុម័ត ។ ប្រធាន គ.ផ.ថ ឬតំណាងផ្ទេរសិទ្ធ ត្រូវរៀបចំសេចក្តីថ្លែងហេតុសង្ខេបពីខ្លឹមសារនៃសេចក្តីព្រាង ជូនអង្គប្រជុំធ្វើការពិភាក្សាសំរេចចិត្តនិងអនុម័ត ។ ការអនុម័តដែលអាចយកជាការបាន គឺត្រូវមានសំលេងគាំទ្រភាគច្រើនដាច់ខាតពីសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ទាំងមូល (*មាត្រា២២នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់*) ។

៣. ក្នុងពេលអនុម័ត ប្រសិនបើមានសំឡេងឆ្នោតស្មើគ្នា សំឡេងរបស់អធិបតីនៃអង្គប្រជុំមានឧត្តមានុភាព (*មាត្រា២២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់*) ។

៤. កម្មវិធីវិនិយោគឃុំសង្កាត់ដែលបានអនុម័តរួចហើយ ត្រូវរក្សាទុកនៅសាលាឃុំសង្កាត់១ច្បាប់ នៅសាលាស្រុកខណ្ឌមួយច្បាប់ដើម្បីរក្សាទុកជាឯកសារ នៅអង្គភាពមូលដ្ឋានរដ្ឋបាលខេត្ត ក្រុងមួយច្បាប់ និងនៅមន្ទីរផែនការខេត្តក្រុងមួយច្បាប់ ។ ត្រូវផ្តល់លទ្ធភាពប្រើប្រាស់ឯកសារដែលបានអនុម័តនេះ អោយបានទូលាយសំរាប់កិច្ចពិគ្រោះយោបល់ជាសាធារណៈ (*ប្រការ១៩នៃប្រកាសអន្តរក្រសួងស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំសង្កាត់*)។